

# សិទ្ធិមនុស្សនៅកម្ពុជា៖
# ការតំរាមកំហែងអ្នកការពារសិទ្ធិមនុស្ស ឆ្នាំ២០០៥

២
០
០
៥

របាយការណ៍ លីកាដូ
ខែកក្កដា ឆ្នាំ២០០៦


លីកាដូ

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

LICADHO

CAMBODIAN LEAGUE FOR THE
PROMOTION AND DEFENSE OF HUMAN RIGHTS

LICADHO

# សិទ្ធិមនុស្សនៅកម្ពុជា:

## ការគំរាមកំហែងអ្នកការពារសិទ្ធិមនុស្ស ឆ្នាំ២០០៥

---

របាយការណ៍ លីកាដូ

ខែកក្កដា ឆ្នាំ២០០៦

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENCE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើត ឡើងនៅឆ្នាំ ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ តាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទីជាអ្នកតស៊ូមតិ សម្រាប់ប្រជាពលរដ្ឋ នឹងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាម សាខា ទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

លីកាដូ កំពុងបន្តសកម្មភាពរបស់ខ្លួនតាមរយៈការិយាល័យកម្មវិធីទាំង ៧ របស់ខ្លួន ដូចខាងក្រោម:

- **ការិយាល័យឯកសារ និងធនធានព័ត៌មានៈ** គឺជាការិយាល័យ ដែលរក្សាចងក្រងសំណុំរឿងនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីងាយស្រួលក្នុងការស្វែងរកឯកសារ នឹងវិភាគអោយបានឆាប់រហ័ស។
- **ការិយាល័យអប់រំសិទ្ធិមនុស្សៈ** គឺជាការិយាល័យដែលបើកវគ្គបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ក្រុមគោលដៅនានាដូចជា មន្ត្រីរាជការ សិស្សនិស្សិត ព្រះសង្ឃព្រមទាំងបើកវគ្គផ្សព្វផ្សាយសិទ្ធិមនុស្សដល់សាធារណៈជននានាថែមទៀតផង។
- **ការិយាល័យស៊ើបអង្កេតៈ** គឺជាការិយាល័យដែលមានតួនាទីជាអ្នកស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្ស និងជួយជនរងគ្រោះនានា ក្នុងដំណើរការបណ្តឹងដែលពាក់ព័ន្ធខាងផ្នែកច្បាប់។ បុគ្គលិកដែលមានការហ្វឹកហ្វឺនជំនាញត្រឹមត្រូវ ក៏បានឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីវាយតម្លៃស្ថានភាពពន្ធនាគារ ព្រមទាំងជួយអោយពិរុទ្ធជនទាំងឡាយទទួលបាននូវតំណាងផ្នែក ច្បាប់ទៀតផង។
- **ការិយាល័យពេទ្យៈ** គឺជាការិយាល័យដែលផ្តល់សេវាវេជ្ជសាស្ត្រដល់ពិរុទ្ធជន ទណ្ឌិត និងមន្ត្រីពន្ធនាគារនៅតាមពន្ធនាគារចំនួន ១៨ កន្លែង។ ក្រៅពីនេះ ក៏បានផ្តល់សេវាវេជ្ជសាស្ត្រ និងជួយបញ្ជូនជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្សទៅមន្ទីរពេទ្យផងដែរ។
- **កម្មវិធីប្រឆាំងនឹងទារុណ្ណកម្មៈ** គឺជាការិយាល័យផ្តល់សេវាកម្មស្តារលទ្ធភាពទូទៅដល់ជនរងគ្រោះដោយអំពើទារុណ្ណកម្ម និងធ្វើការតស៊ូមតិប្រឆាំងនឹងអំពើទារុណ្ណកម្ម។
- **ការិយាល័យសិទ្ធិកុមារៈ** ជាការិយាល័យដែលផ្តល់ការអប់រំសិទ្ធិកុមារដល់សាធារណៈជនទូទៅ ស្តាបនាបណ្តាញការពារកុមារនៅតាមមូលដ្ឋាននានា និងស៊ើបអង្កេតការរំលោភសិទ្ធិកុមារ ។
- **ការិយាល័យសិទ្ធិស្ត្រីៈ** ជាការិយាល័យអប់រំសិទ្ធិស្ត្រីដល់សាធារណៈជនទូទៅ ស៊ើបអង្កេតការរំលោភសិទ្ធិស្ត្រី និងធ្វើការតស៊ូមតិដើម្បីអោយមានការផ្លាស់ប្តូរផ្នែកច្បាប់ និងសង្គម។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការលីកាដូ

អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦, ផ្លូវលេខ ៩៩, រាជធានីភ្នំពេញ, កម្ពុជា

ទូរស័ព្ទ:(៨៥៥) ២៣ ៣៦០ ៩៦៥ / ៣៦៤៩០១ , ទូរសារ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ២១៧ ៦២៦

អ៊ីមែល: contact@licadho.org

គេហទំព័រ: http://www.licadho.org/

# មាតិការឿង


**សង្ខេបប្រតិបត្តិ** ..... **១**

**I. សេចក្តីផ្តើម** ..... **៣**

អ្នកការពារសិទ្ធិមនុស្ស - តើពួកគេជានរណា ? ..... ៣

កិច្ចការពារស្របច្បាប់ចំពោះអ្នកការពារសិទ្ធិមនុស្ស ..... ៤

**II. បរិយាកាសប្រតិបត្តិការសំរាប់អ្នកការពារសិទ្ធិមនុស្ស** ..... **៥**

សាវតា ..... ៥

ការបដិសេធសេរីភាពនៃការបញ្ចេញមតិ ..... ៥

ការបដិសេធសិទ្ធិជួបប្រជុំដោយសន្តិវិធី ..... ៩

ទំនាស់ដីធ្លី ..... ១០

ការបង្ហាញជាសាធារណៈនូវអ្នកការពារសិទ្ធិមនុស្ស ..... ១២

**III. ការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិនៅឆ្នាំ២០០៥** ..... **១៥**

អំពើហិង្សា និងអំពើមនុស្សឃាត ..... ១៥

ការគំរាមកំហែង ការបំភិតបំភ័យ និងការយាយី ..... ១៦

ការរឹតត្បិតលើការងារ និងការធ្វើដំណើរ ..... ១៦

ទោសព្រហ្មទណ្ឌ វិធានការរដ្ឋប្បវេណី ការចាប់ខ្លួន និងការឃុំខ្លួនខុសច្បាប់ ..... ១៧

ការវិវឌ្ឍនៅឆ្នាំ២០០៦ ..... ១៨

**IV. ផលប៉ះពាល់នៃការគំរាមកំហែងចំពោះការងារសិទ្ធិមនុស្ស** ..... **២០**

ផលប៉ះពាល់ចំពោះសកម្មជនសិទ្ធិមនុស្ស ..... ២០

ផលប៉ះពាល់ចំពោះសង្គម ..... ២០

**V. អនុសាសន៍** ..... **២២**

រដ្ឋាភិបាលកម្ពុជា ..... ២២

រដ្ឋាភិបាលបរទេស ស្ថានទូត និងម្ចាស់ជំនួយ ..... ២២

អង្គការសិទ្ធិមនុស្សកម្ពុជា និងអន្តរជាតិ ..... ២៣

**ឧបសម្ព័ន្ធទី១ : តារាងឧបទ្ទវហេតុពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៥** ..... **២៤**

# សេចក្ដីសង្ខេប

ស្ថានភាពអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា មានការធ្លាក់ចុះគួរអោយកត់សម្គាល់នៅឆ្នាំ២០០៥ ។ អ្នកតស៊ូមតិសិទ្ធិមនុស្ស សកម្មជនតាមសហគមន៍ អ្នកដឹកនាំសហជីពកម្មករ ស្ថិតនៅក្នុងចំណោមមុខសញ្ញា ដោយសារពួកគេបំពេញការងារការពារសិទ្ធិមនុស្សជាមូលដ្ឋានរបស់ខ្លួន ។ ការបំភិតបំភ័យដែលអ្នកទាំងនេះបានប្រឈម រួមមានការវាយប្រហារផ្នែករូបកាយ និងពាក្យសម្ដី ការប្ដឹងផ្ដល់ដែលមានចេតនាមិនល្អ និងការចោទប្រកាន់បទព្រហ្មទណ្ឌ ការចាប់ខ្លួន និងការឃុំខ្លួនជាដើម។ ទង្វើទាំងនេះកើតមានជាញឹកញាប់នៅក្នុងឆ្នាំដែលកត់សម្គាល់ដោយការវាយ ប្រហារទៅលើសង្គមស៊ីវិល និងភាពគ្មានការអត់អោនកាន់តែខ្លាំងឡើងចំពោះការរិះគន់រដ្ឋាភិបាល ។

ទោះបីអំពើហិង្សាផ្នែករូបរាងកាយទៅលើអ្នកការពារសិទ្ធិមនុស្សបានថយចុះនៅប៉ុន្មានឆ្នាំថ្មីៗនេះក៏ដោយ ក៏មានការបង្វែរទិសឆ្ពោះទៅរកការបង្ខិតបង្ខំ និងការបំភិតបំភ័យជាទម្រង់ដទៃទៀត ដោយការប្រើប្រាស់ផ្លូវច្បាប់មិនច្បាស់លាស់។ និន្នាការនេះត្រូវបានអនុវត្តបន្តនៅឆ្នាំ២០០៥ ដោយមានការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ការរីតបន្តឹងសន្តិសុខ និងដាក់លក្ខខណ្ឌចុះបញ្ជីស្មាមក្នុងគោលបំណង ដើម្បីបង្ក្រាបការងារសិទ្ធិមនុស្ស ។ ទង្វើទាំងនេះ គឺជាសារដំណឹងមួយសំរាប់ប្រជាពលរដ្ឋកម្ពុជាថា សិទ្ធិមនុស្ស គឺជាបុព្វសិទ្ធិដែលរដ្ឋាភិបាលជាអ្នកផ្ដល់អោយ ហើយអាចដក ហូតវិញនៅពេលណាក៏បាន ។

ការចុះហត្ថលេខាលើសន្ធិសញ្ញាព្រំដែនដ៏នៅចុងឆ្នាំ២០០៥ បង្ហាញពីការដាក់កំហិតលើការបញ្ចេញមតិដោយសេរីនៅកម្ពុជា បង្កអោយមានការចោទប្រកាន់ពីបទបរិហាកេរ្ដិ៍ជាទោសព្រហ្មទណ្ឌប្រឆាំង នឹងអ្នកដឹកនាំសង្គមស៊ីវិលទាំងឡាយ ។ អ្នកបំរើការសិទ្ធិមនុស្សឋានៈសំខាន់ៗដែលពុំបានបញ្ចេញយោបល់ទាក់ទងទៅនឹងបទបរិហាកេរ្ដិ៍នោះ ក៏ត្រូវក្លាយជាមុខសញ្ញាចាប់ខ្លួនផងដែរ ។ ការចាប់ខ្លួនមិនត្រឹមត្រូវខុសនឹងនីតិវិធី និងរំលោភបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ គឺជាការរំលោភដោយឥតលាក់លៀមលើការបែងចែករវាងអំណាចនីតិប្រតិបត្តិ និងអំណាចតុលាការព្រមទាំងបង្កើតអោយមានបរិយាកាសភ័យខ្លាចនៅក្នុងសង្គមស៊ីវិល ។ មានសកម្មជនសិទ្ធិមនុស្ស និងអ្នកដឹកនាំសង្គមស៊ីវិលជាច្រើនត្រូវរត់គេចខ្លួនពីប្រទេស ឯអ្នកផ្សេងទៀត ត្រូវបំភិតបំភ័យមិនហ៊ានបញ្ចេញមតិ ។

ទោះបីបណ្ដឹងផ្លូវការចេញដោយរដ្ឋាភិបាលក៏ដោយ ក៏សម្ដេចនាយករដ្ឋមន្ត្រីមានប្រតិកម្មខ្លាំងជាសាធារណៈថា នឹងដាក់ពន្ធនាគារអ្នកដែលរិះគន់លោក ដែលនេះបង្ហាញអោយឃើញច្បាស់ដោយគ្មានសង្ស័យថានរណាជាអ្នកផ្ដួចផ្ដើមការចោទប្រកាន់និងការចាប់ខ្លួនទាំងនោះ ។ ក្រោយពីមានអន្តរាគមន៍ពីសំណាក់រដ្ឋាភិបាលសហរដ្ឋអាមេរិក នាំទៅដល់ការដោះលែងសកម្មជន ដែលជាប់ឃុំឃាំងនៅឆ្នាំ២០០៦កន្លងមក សម្ដេចនាយករដ្ឋមន្ត្រីជាអ្នកផ្ដល់ការធានាអោយនៅក្រៅឃុំ ដែលស្ដែងបញ្ជាក់ថា សេរីភាពរបស់អ្នកទាំងនេះ គឺស្ថិតនៅក្រោមឆន្ទានុសិទ្ធិផ្ទាល់ពីសម្ដេចនាយករដ្ឋមន្ត្រី ។ ការយកអ្នកការពារសិទ្ធិ

មនុស្ស ជាមុខសញ្ញារបស់សម្តេចនាយករដ្ឋមន្ត្រី គឺជាគំរូមិនល្អសំរាប់អ្នកឯទៀតនៅក្នុងរដ្ឋាភិបាល ។

អ្នកការពារសិទ្ធិមនុស្ស ត្រូវទទួលរងទុក្ខវេទនាជាខ្លាំងដោយសារផលវិបាកនៃទង្វើទាំងនេះ ។ សហគមន៍អន្តរជាតិ រិះគន់យ៉ាងខ្លាំងចំពោះការចាប់ខ្លួនទាំងនេះ ប៉ុន្តែ រដ្ឋាភិបាលមានការស្ទាក់ស្ទើរក្នុងការលះបង់ ដើម្បីអនុវត្តតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ។ ជាការគួរអោយខកចិត្តដែលអ្នកដឹកនាំកម្ពុជានៅបន្តប្រើប្រាស់ការបំភិតបំភ័យ ដើម្បីដឹកនាំប្រទេស ក្នុងខណៈពេលដែលសង្គមត្រូវការយ៉ាងខ្លាំងនូវសេចក្តីសង្ឃឹម និងទំនុកចិត្តដោយការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ។

របាយការណ៍សង្ខេបនេះ ផ្តល់នូវការវិភាគមួយអំពីការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជានៅអំឡុងឆ្នាំ ២០០៥ ។ ឯកសារនេះក៏មាននិយាយផងដែរអំពីការចាប់ខ្លួនលោក ប៉ា ងួនទៀង នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០០៦ និងសេចក្តីសង្ខេបអំពីការវិវឌ្ឍដែលពាក់ព័ន្ធនៅដើមឆ្នាំ២០០៦ ។ ឯកសារនេះ ផ្អែកតាមការស៊ើបអង្កេត និងព័ត៌មានដទៃទៀត ដែលចងក្រងដោយអង្គការសម្ព័ន្ធជំរឿនខ្មែរ និង ការពារសិទ្ធិមនុស្ស-លីកាដូ (Cambodian League for the Promotion and Defense of Human Rights-LICADHO) និងដោយមានការគាំទ្របន្ថែម ពីការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំនៅកម្ពុជា (United Nations Cambodia Office of the High Commissioner for Human Rights-UNCOHCHR) និងសមាគមកម្ពុជាដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ (Cambodian Association for Human Rights and Development-ADHOC ។

# I. សេចក្តីផ្តើម

## អ្នកការពារសិទ្ធិមនុស្ស – តើពួកគេជានរណា ?

អ្នកការពារសិទ្ធិមនុស្ស គឺជាមនុស្សដែលជាបុគ្គល ឬរួមជាមួយអ្នកដទៃទៀត ធ្វើសកម្មភាពដើម្បីលើកស្ទួយ ឬការពារសិទ្ធិមនុស្សជាមូលដ្ឋានតាមវិធីអហិង្សា ។ អ្នកការពារសិទ្ធិមនុស្ស អាចជាផ្នែកមួយរបស់អង្គការជាតិតាមផ្លូវការ ឬអន្តរជាតិតាមផ្លូវការ ឬអាចធ្វើការនៅក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួន ។ ជារឿយៗ អ្នកការពារសិទ្ធិ គឺជាបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល អ្នកដឹកនាំសហជីពកម្មករ អ្នកសារព័ត៌មាន អ្នកដឹកនាំសហគមន៍ គ្រូបង្រៀន ឬនិស្សិត ប៉ុន្តែអាចជានរណាម្នាក់ក៏បាន ដោយមិនគិតដល់វិជ្ជាជីវៈធម្មតារបស់ពួកគេទេ ។ បច្ចុប្បន្ននេះ កម្ពុជាមានសហគមន៍អ្នកការពារសិទ្ធិមនុស្សយ៉ាងរឹងមាំ និងសកម្ម ព្រមទាំងអង្គការសិទ្ធិមនុស្សនានា ដែលបំពេញតួនាទីជាចំបងក្នុងការលើកស្ទួយ និងបង្កើនសិទ្ធិមនុស្ស ។ សហគមន៍នេះបានអភិវឌ្ឍន៍តាំងពីឆ្នាំ១៩៩១ នៅពេលដែលអង្គការមិនមែនរដ្ឋាភិបាលសិទ្ធិមនុស្សលើកដំបូង ត្រូវបានបង្កើតឡើងក្រោយពីមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនាទីក្រុងប៉ារីស ។

ក្រៅពីការពណ៌នាជាទូទៅនេះ អង្គការនានាមានរបៀបខុសគ្នាបន្តិចបន្តួចក្នុងការកំណត់និយមន័យនៃអ្នកការពារសិទ្ធិមនុស្ស ។ ក្នុងការកំណត់ថា តើករណីមួយអាចជាការគំរាមកំហែងដល់អ្នកការពារសិទ្ធិមនុស្សម្នាក់ ឬយ៉ាងណានោះ លីកាដូ យល់ឃើញថាជាការសំខាន់ត្រូវកំណត់ថា តើជនរងគ្រោះបានធ្វើសកម្មភាពដែលការពារ ឬលើកស្ទួយសិទ្ធិមនុស្សដូចដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស និងត្រូវបានធានាដោយបរិធានអន្តរជាតិនានា ដូចជាកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយដែរឬទេ? -សកម្មភាពដូចពោលនេះ ត្រូវធ្វើឡើងទាំងស្រុង ឬមួយផ្នែកតំណាង អោយអ្នកដទៃមិនមែនដើម្បីប្រយោជន៍ផ្ទាល់ខ្លួនឡើយ ។ តាមរយៈការពិនិត្យពិច័យនូវភស្តុតាង ដែលមានត្រូវបង្ហាញអោយឃើញនូវទំនាក់ទំនងជាមូលហេតុច្បាស់លាស់រវាងសកម្មភាពដែលបានអនុវត្ត ដើម្បីការពារសិទ្ធិមនុស្សការគំរាមកំហែង ការរំខាន ការបៀតបៀន ឬការបំភិតបំភ័យដែលបានទទួលរង ។

សូមកត់សម្គាល់ថា ទោះបីអ្នកនយោបាយអាចធ្វើសកម្មភាពជាអ្នកការពារសិទ្ធិមនុស្ស ដូចជាអ្នកដទៃទៀតក៏ដោយ អាជ្ញាធរគ្រប់គ្រងអំណាចនៅក្នុងប្រទេស ដែលមានកំណត់ត្រាសិទ្ធិមនុស្សមិនល្អ ដូចជាប្រទេសកម្ពុជាជាដើម តែងតែព្យាយាមបង្ខូចឈ្មោះអង្គការសិទ្ធិមនុស្សអព្យាក្រឹត ដោយភ្ជាប់អង្គការសិទ្ធិមនុស្សទាំងនោះទៅនឹងគណៈបក្សនយោបាយជំទាស់ ។ ដើម្បីចៀសវាងការចោទប្រកាន់លំអៀងទៅរកគណបក្សនយោបាយ និងចង្អុលបង្ហាញអំពីការការពារផ្សេង ដែលអ្នកនយោបាយអាចរកបានក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ការគំរាមកំហែងដែលអ្នកនយោបាយជាតិបានទទួលមិនមែនបញ្ចូលជាករណីគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សនៅក្នុងរបាយការណ៍នេះទេ ។

## កិច្ចការពារស្របច្បាប់ចំពោះអ្នកការពារសិទ្ធិមនុស្ស

នៅកម្ពុជា កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ បានផ្តល់ជាមូលដ្ឋានច្បាប់សំរាប់ការពារអ្នកការពារសិទ្ធិមនុស្ស ដូចជាការទទួលស្គាល់សិទ្ធិសេរីភាពក្នុងការបង្កើតសមាគម ការជួបប្រមូលផ្តុំ និងការបញ្ចេញមតិជាដើម ។ នៅឆ្នាំ១៩៩២ រដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័នទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ មានដូចជាកតិកាសញ្ញា អន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយ (International Covenant on Civil and Political Rights-ICCPR) កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (International Covenant on Economic, Social and Cultural Rights-ICESCR) ។ បទបញ្ញត្តិនៃកតិកាសញ្ញាទាំងពីរនេះ និងសេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្សទាំងនេះ ត្រូវបានបញ្ចូលនៅក្នុងច្បាប់ក្នុងស្រុក ដោយរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ។

នៅឆ្នាំ១៩៩៨ នៅក្នុងឱកាសខួបលើកទី៥០ នៃសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តទទួលយកជាឯកឆន្ទនូវសេចក្តីប្រកាសស្តីអំពីទំនួលខុសត្រូវរបស់បុគ្គល ក្រុម និងស្ថាប័នសង្គម ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន[១] ដែលមានការទទួលស្គាល់ជាសកល ។ សេចក្តីប្រកាសនេះបានក្លាយជា "សេចក្តីប្រកាសស្តីអំពីអ្នកការពារសិទ្ធិមនុស្ស" ។

សេចក្តីប្រកាសនេះ មានចែងអំពីសិទ្ធិ និងការការពារចំពោះអ្នកការពារសិទ្ធិ ដែលគាំទ្រដោយប្រទេសជាសមាជិក ដូចជា សិទ្ធិស្វែងរកមាន ទទួលបាន និងរក្សាទុកព័ត៌មានទាក់ទងនឹងសិទ្ធិមនុស្ស ឬរិះគន់ការមិនគោរពបទដ្ឋាន សិទ្ធិមនុស្សរបស់រដ្ឋាភិបាលជាដើម ។ តំណាងពិសេសនៃអគ្គលេខាធិការទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្ស បានធ្វើការកត់សម្គាល់ថា សេចក្តីប្រកាសនេះផ្អែកតាមគោលការណ៍ជាកាតព្វកិច្ចតាមផ្លូវច្បាប់ និងជាសិទ្ធិដែលមានកំណត់រួចនៅក្នុងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលមានស្រាប់ ហើយដោយសារ "សេចក្តីប្រកាសនេះ ត្រូវបានអនុម័តទទួលយកជាឯកឆន្ទដោយមហាសន្និបាតអង្គការសហប្រជាជាតិ... ដូច្នេះ វាតំណាងអោយការប្តេជ្ញាចិត្តដ៏មុតមាំរបស់ប្រទេសនានា ដើម្បីនឹងអនុវត្តសេចក្តីប្រកាសនេះ"[២] ។

---

១ អង្គការសហប្រជាជាតិ ឯកសារយោង : A/RES/53/144 ។ ចេញផ្សាយថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៩៩ ។

២ សូមមើលឧបសម្ព័ន្ធទី២ : សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីអំពីអ្នកការពារសិទ្ធិមនុស្ស ដែលអាចរកបាននៅក្នុងបណ្តាញអ៊ីនធឺណិត http://www.unhchr.ch/huridocda/huridoca.nsf/(Symbol)/A.RES.53.144.En?OpenDocument ។

# II. បរិយាកាសប្រតិបត្តិការសំរាប់អ្នកការពារសិទ្ធិមនុស្ស

## កាលប្រវត្តិ

សង្គមកម្ពុជា នៅមានមរតករបបខ្មែរក្រហមនៅឡើយ (១៩៧៥-១៩៧៩) ដែលនៅអំឡុងរបបនេះ ប្រជាពលរដ្ឋកម្ពុជាប្រមាណជា ១,៧ លាននាក់បានស្លាប់ ។ មានការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរបំផុតនៅទូទាំងប្រទេស ដូចជាការធ្វើទារុណកម្ម ការសម្លាប់ ការធ្វើពលកម្មដោយបង្ខំ ការបង្អត់អាហារ និងការរំលោភសេពសន្ថវៈជាដើម ។ អ្នកមានវិជ្ជាជីវៈស្ទាត់ជំនាញភាគច្រើនត្រូវគេសម្លាប់ គ្មានបន្សល់ទុកនូវអ្នកចេះដឹងនៅក្នុងសង្គមឡើយ ។ ទោះបីរបបខ្មែរក្រហមត្រូវបញ្ចប់នៅឆ្នាំ១៩៧៩ ទៅហើយក្តី ក៏សង្គ្រាមស៊ីវិលនៅតែបន្តរហូតដល់ចុងទសវត្សរ៍ឆ្នាំ១៩៩០ ដោយសារក្រុមនយោបាយផ្សេងៗតស៊ូដណ្តើមអំណាចគ្នា ។ ការបង្កើតឡើងនូវអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ( UN Transitional Authority in Cambodia-UNTAC) នៅឆ្នាំ១៩៩២ បានបង្កើតឱកាសអោយមានការងើបឡើងវិញ និងការកសាងសង្គមស៊ីវិលឡើងវិញ ។

បរិបថនយោបាយនៅកម្ពុជា រងឥទ្ធិពលពីប្រវត្តិសាស្ត្រហិង្សារបស់ខ្លួន ។ កាលពីអតីតកាល កម្ពុជាធ្លាប់មានប្រវត្តិការពារសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក្សត់ខ្សោយ ។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងអន្តរកាលដ៏មិនប្រាកដប្រជាឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យ ហើយជារឿយៗ មិនសូវបានបំពេញកាតព្វកិច្ចរបស់ខ្លួននៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងនយោបាយ ព្រមទាំងកតិកាសញ្ញាស្តីអំពីសិទ្ធិ សេដ្ឋកិច្ចសង្គម និងវប្បធម៌ឡើយ ។

ជាងនេះទៅទៀត ស្ថានភាពសេដ្ឋកិច្ចរបស់កម្ពុជានៅទន់ខ្សោយនៅឡើយ ។ ភាពក្រីក្រនៅតែមានយ៉ាងច្បាស់ក្រឡែត ដោយប្រាក់ចំណូលមធ្យមប្រចាំឆ្នាំបានតែ ៣២០ ដុល្លារសហរដ្ឋអាមេរិកប៉ុណ្ណោះ[៣] ។ លទ្ធផលផ្ទាល់ គឺជីវភាពរស់នៅមានកំរិតទាប ស្ថានភាពសុខភាពខ្សោយ ខ្វះលទ្ធភាពទទួលការអប់រំគ្រប់គ្រាន់ អាយុមរណៈកាលជាមធ្យមបានតែ ៥៤ ឆ្នាំប៉ុណ្ណោះ[៤] ។ ច្បាប់ទាក់ទងនឹងដីធ្លី និងធនធានគ្មានប្រសិទ្ធភាព នៅតែបន្តមានផលប៉ះពាល់ធ្វើអោយអន្តរាយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជានៅតាមតំបន់ជនបទ ។ ផ្ទៃដីកសិកម្ម និងព្រៃឈើធំៗត្រូវបានផ្ទេរទៅអោយផ្នែកឯកជន ហើយមានការរឹបអូសដីដោយខុសច្បាប់ដោយក្រុម ឬបុគ្គលមានអំណាច ។

ជាអកុសល យោងតាមរបាយការណ៍ អ.ស.ប. នៅអំឡុងឆ្នាំ២០០៥ មាននិន្នាការកើនឡើងឆ្ពោះទៅរករដ្ឋាភិបាលផ្តាច់

[៣] ការប៉ាន់ស្មានរបស់អង្គការ UNICEF ឆ្នាំ២០០៤ មាននៅក្នុង http://www.unicef.org/infobycountry/cambodia_statistics.html2 ។

[៤] ស្ថិតិធនាគារពិភពលោក ឆ្នាំ២០០៤ ។

ការ[៥] ។ អាជ្ញាធរនៅតែបន្តរឹតត្បិតតាមទំនើងចិត្តចំពោះការបញ្ចេញមតិជាសាធារណៈ ការប្រមូលផ្តុំ និងការបង្កើតសមាគម ។ អាជ្ញាធរទាំងនោះបានតម្រង់គោលដៅទៅរកអ្នកនយោបាយជំទាស់ អ្នកដឹកនាំសង្គមស៊ីវិល អ្នកសារព័ត៌មាន និងអ្នកតវ៉ាដោយសន្តិវិធី ដោយការចាប់ខ្លួនខុសច្បាប់ ការរំលោភនីតិវិធីច្បាប់ ការគំរាមកំហែង និងការឃាយឺដទៃទៀត ។ ជាមួយគ្នានេះដែរ ការកាប់ទន្រ្ទានវាតដីដោយគ្មានការទប់ស្កាត់ នៅតែបន្តបង្កការគំរាមកំហែងដល់ជីវភាពរស់នៅ ហើយជាបុព្វហេតុនាំអោយមានទំនាស់កាន់តែខ្លាំងឡើង រវាងសកម្មជនសិទ្ធិមនុស្សក្នុងមូលដ្ឋាន និងអង្គភាពរដ្ឋ ឬឯកជន ដែលជាធម្មតាមានការគាំទ្រពីកងកម្លាំងសន្តិសុខ ។

ស្ថានភាពទាំងនេះ រួមផ្សំនឹងកត្តាដទៃទៀត បង្កើតអោយមានបរិយាកាសប្រតិបត្តិការដ៏លំបាក និងគ្រោះថ្នាក់ចំពោះអ្នកការពារសិទ្ធិមនុស្សនៅឆ្នាំ២០០៥ ។ បញ្ហានេះរឹតតែយ៉ាប់យ៉ឺនទៅទៀតដោយសារមន្ត្រី និងអ្នកជិតស្និទ្ធនឹងរដ្ឋាភិបាលមានទំនោរបើកការវាយប្រហាររិះគន់ជាសាធារណៈទៅលើអ្នកការពារសិទ្ធិមនុស្ស ដោយបង្ហាញអោយឃើញថា អ្នកការពារសិទ្ធិមនុស្ស គឺជាអ្នកអាណិតអាសូរដល់ឧក្រិដ្ឋជន ដែលបំផ្លាញសង្គមកម្ពុជា ។

## ការបដិសេធសេរីភាពនៃការបញ្ចេញមតិ

សេរីភាពបញ្ចេញមតិ ត្រូវបានកាត់បន្ថយជាលក្ខណៈប្រព័ន្ធនៅឆ្នាំ២០០៥ ដោយសាររដ្ឋាភិបាលនៅតែបន្ត និងបង្កើនការប្រើប្រាស់នីតិវិធីច្បាប់មិនត្រឹមត្រូវរបស់ខ្លួន ដើម្បីចាប់អ្នករិះគន់ខ្លួន និងអ្នកជំទាស់នយោបាយដាក់ពន្ធនាគារ ។ អ្នកដឹកនាំសង្គមស៊ីវិល អ្នកសារព័ត៌មាន និងអ្នកដឹកនាំសហជីពកម្មករ ព្រមទាំងសមាជិកសភាគណៈបក្សជំទាស់បានក្លាយជាមុខសញ្ញានៃការប្តឹងផ្តល់ពីបទបរិហារកេរ្តិ៍ដូចផ្តើមឡើងដោយរដ្ឋាភិបាល ។ ការកាត់ទោសមានឥទ្ធិពលគួរអោយភ័យខ្លាចទៅលើសង្គមស៊ីវិល បន្ទាប់មកមានការចាប់ខ្លួនស្រដៀងគ្នានេះទៅលើអ្នកការពារសិទ្ធិមនុស្សទៀតផង ។

នៅខែកុម្ភៈ ឯ. ឧ. សម រង្ស៊ី មេដឹកនាំគណៈបក្សជំទាស់ និងសមាជិកសភាដូចលោកដែរ គឺ ឯ. ឧ. ជា ប៉ូច និងឯ. ឧ. ជៀម ចន្ទី ត្រូវគេដកអភ័យឯកសិទ្ធិ ទុកឱកាសអោយមានការកាត់ទោសទាក់ទងនឹងការចោទប្រកាន់មិនច្បាស់លាស់ជាច្រើន ។ បណ្តឹងពីបទព្រហ្មទណ្ឌទទួលបរាជ័យមួយធ្វើឡើងដោយឯ.ឧ.សម សង្ស៊ី ចំពោះសម្តេចនាយករដ្ឋមន្ត្រី អំពីការពាក់ព័ន្ធនៅក្នុងការវាយប្រហារដោយគ្រាប់បែកដែលបណ្តាលអោយមានការបាត់បង់ជីវិត កាលពីថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៩៧ ធ្វើអោយឯ.ឧ. សម រង្ស៊ី ប្រឈមមុខនឹងការចោទប្រកាន់បទព្រហ្មទណ្ឌថាបានបរិហារកេរ្តិ៍លោកនាយករដ្ឋមន្ត្រីទៅវិញ ។ ឯ.ឧ.សម រង្ស៊ី និងឯ.ឧ. ជា ប៉ូច ក៏ត្រូវប្រឈមមុខនឹងការចោទប្រកាន់ ដោយសារបានចោទប្រកាន់អំពីអំពើពុករលួយ នៅក្នុងការបង្កើតរដ្ឋាភិបាលចំរុះរវាងគណៈបក្សប្រជាពលរដ្ឋកម្ពុជា និងគណៈបក្សហ៊្វុនស៊ិនប៉ិចផងដែរ ។ អ្នកទាំងពីរត្រូវរត់គេចខ្លួនចេញពីប្រទេស ចំណែកឯ.ឧ. ជៀម

[៥] សេចក្តីប្រកាសព័ត៌មានរបស់អង្គការសហប្រជាជាតិ តំណាងពិសេសរបស់អគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ការដកអភ័យឯកសិទ្ធិសមាជិករដ្ឋសភា នៃគណៈបក្ស សម សង្ស៊ី និងការចាប់ខ្លួនឯ.ឧ. ជៀម ចន្ទី ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥។

ចន្ទី ត្រូវបានចាប់ខ្លួនដោយខុសច្បាប់ដោយកងរាជអាវុធហត្ថ និងត្រូវឃុំខ្លួននៅក្នុងពន្ធនាគារយោធា ក្រោមការចោទប្រកាន់ថាបាន បង្កើតកងទ័ពខុសច្បាប់ ។ នៅខែសីហា ឯ.ឧ. ជៀម ចន្ទី ត្រូវបានគេកាត់ទោសអោយជាប់ពន្ធនាគារចំនួន ៧ ឆ្នាំ ដោយតុលាការយោធានៅក្នុងការកាត់ក្តីមួយ ដែលត្រូវបានគេថ្កោលទោសជាទូទៅថាមានហេតុផលនយោបាយ និងភាពមិនស្របច្បាប់ ។

នៅខែធ្នូ ឯ.ឧ. សម រង្ស៊ី ត្រូវបានកាត់ទោសដោយកំបាំងមុខពីបទបរិហាកេរ្តិ៍ទាំងពីរ រួចត្រូវផ្តន្ទាទោសអោយជាប់ពន្ធនាគារចំនួន ១៨ ខែ ។ ជាផ្នែកមួយនៃដោះដូរ ដើម្បីអោយបានការលើកលែងទោសជាយថាហេតុ ការវិលត្រឡប់មកកម្ពុជាវិញ និងការដោះលែងឯ.ឧ. ជៀម ចន្ទី គឺត្រូវដកការចោទប្រកាន់របស់លោក និងការព្រមព្រៀងបោះបង់បណ្តឹងចំពោះសម្តេចនាយករដ្ឋមន្ត្រី ពីករណីវាយប្រហារដោយគ្រាប់បែកនៅឆ្នាំ១៩៩៧ ដែលរង់ចាំការកាត់ក្តីនៅតុលាការអាមេរិក ។ ទោះបីអ្នកនយោបាយមិនស្ថិតនៅក្នុងនិយមន័យអ្នកការពារសិទ្ធិមនុស្សក៏ដោយ ចំពោះរបាយការណ៍នេះ ការវាយប្រហារដោយសម្លេងប្រតិកម្មជំទាស់ខ្លាំងៗពីថ្នាក់ដឹកនាំនៅក្នុងប្រទេសដូច្នេះ ក៏ជាការបង្ហាញអំពីទង្វើរបស់រដ្ឋាភិបាលចំពោះអ្នកការពារសិទ្ធិមនុស្សដែរ ។



លោក ម៉ម សូណង់ដូ

មានប្រសាសន៍តៅកាន់អ្នកកាសែត

ការភ័យខ្លាចពីប្រតិកម្មតបរបស់រដ្ឋាភិបាលទៅលើការរិះគន់ នឹងឈានទៅដល់ការវាយប្រហារទៅលើសង្គមស៊ីវិល និងសេរីភាពនៃការបញ្ចេញមតិ បានកើតមានឡើងនៅខែតុលា នៅពេលដែលលោក ម៉ម សូណង់ដូជាម្ចាស់ និងជានាយកស្ថានីយ៍វិទ្យុសំបុកឃ្មុំឯករាជ្យត្រូវបានគេចាប់ខ្លួន ។ លោក ម៉ម សូណង់ដូ ត្រូវគេចោទប្រកាន់ពីបទបរិហាកេរ្តិ៍ផ្សាយព័ត៌មានមិនពិត និងពីបទញុះញង់ ដែលគេអាចប៉ាន់ស្មាននឹងត្រូវកាត់ទោសអោយជាប់ពន្ធនាគារសរុបចំនួន ៩ ឆ្នាំ ។ បទល្មើសព្រហ្មទណ្ឌដែលគេបានចោទប្រកាន់លោកនោះ គឺការផ្សព្វផ្សាយបទសម្ភាសន៍មួយ ដែលលោកបានធ្វើឡើងជាមួយសកម្មជនកម្ពុជាម្នាក់ដែលរស់នៅប្រទេសបារាំង អំពីសន្ធិសញ្ញាព្រំដែនរវាងប្រទេសជិតខាង។ ទោះជាយ៉ាងណាក៏ដោយ បើពិនិត្យស្តាប់អោយបានជិតដល់លើខ្សែអាត់សម្ភាសន៍នោះបង្ហាញថា គ្មានចំណុចត្រង់ណាដែលលោក ម៉ម សូណង់ដូ បានបញ្ចេញការរិះគន់ផ្ទាល់ខ្លួនអំពីសន្ធិសញ្ញានោះ ឬញុះញង់នរណាម្នាក់អោយប្រព្រឹត្តិបទឧក្រិដ្ឋនោះឡើយ តាមពិតក្នុងចំណុចមួយចំនួន លោក ម៉ម សូណង់ដូ គ្រាន់តែដេញដោលសកម្មជននោះអំពីទស្សនៈ របស់ខ្លួនប៉ុណ្ណោះ ។ ប៉ុន្តែ ការចាប់ខ្លួនលោក ម៉ម សូណង់ដូ ហួសពីការធ្វើទុក្ខបុកម្នេញអ្នកសារព័ត៌មានទៅទៀត ។ វិទ្យុសំបុកឃ្មុំ គឺជាប្រភពព័ត៌មានផ្តល់ឯករាជ្យមួយក្នុងចំណោមបណ្តាញព័ត៌ឯករាជ្យមួយចំនួនតូច ដែលផ្សព្វផ្សាយនៅកម្ពុជា ហើយបានជួលម៉ោងផ្សាយអោយទៅវិទ្យុសម្លេងសហរដ្ឋអាមេរិក និងវិទ្យុអាស៊ីសេរី ដែលដំណើរការដោយរដ្ឋាភិបាលអាមេរិក ដែលជាប្រភពមួយមិនស្រប នឹងរដ្ឋាភិបាលកម្ពុជា ដែលជាញឹកញាប់តែងតែហាមឃាត់ការផ្សាយឡើងវិញនូវព័ត៌មាន ដែលមានប្រភពនៅបរទេស[៦] ។

---

[៦] គណៈកម្មការការពារអ្នកសារព័ត៌មាន (Committee to Protect Journalists-CPJ) លោក ម៉ម សូណង់ដូ នៃវិទ្យុសំបុកឃ្មុំ សកម្មភាពស្របច្បាប់ត្រូវជាប់ពន្ធនាគារ :

http://www.cpj.org/cases05/asia_cases05/cambodia.html ។

ជាមួយគ្នានេះដែរ នៅក្នុងខែតុលា លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ត្រូវបានចាប់ខ្លួន នៅពេលព្យាយាមឆ្លងកាត់ព្រំដែនចូលទៅប្រទេសថៃ ដើម្បីស្វែងរកសិទ្ធិជ្រកកោន ។ លោកត្រូវគេចោទប្រកាន់ពីបទ បរិហារកេរ្តិ៍ និងញុះញង់ទាក់ទង នឹងសេចក្តីថ្លែងការណ៍ព័ត៌មានមួយ ដែលលោកបានចូលរួមចុះហត្ថលេខា ជាមួយសមាជិកបីនាក់ទៀតនៃក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា ទាក់ទងនឹងសន្ធិសញ្ញាព្រំដែនកម្ពុជា-វៀតណាមដដែលនោះ[៧] ។

ក្នុងករណីទាំងពីរនេះ តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានរិះគន់ភាពមិនស្របច្បាប់នៃនីតិវិធីចាប់ខ្លួន និងបទបញ្ជាឃុំខ្លួនដោយធ្វើការកត់សំគាល់ផងដែរអំពីលក្ខណៈខ្វះមូលដ្ឋាននៃការចោទប្រកាន់ពីបទញុះញង់នោះ[៨] ។ ជាមួយគ្នានោះដែរ មានបុគ្គលជាច្រើនទៀត ដែលបានបញ្ចេញមតិរិះគន់អំពីសន្ធិសញ្ញានោះក៏ត្រូវបានចោទប្រកាន់ផងដែរ ។

សេរីភាពនៃការបញ្ចេញមតិ ត្រូវបានការពារក្រោមច្បាប់អន្តរជាតិ និងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស ព្រមទាំងរដ្ឋធម្មនុញ្ញកម្ពុជា[៩] ។ ទោះបីបទបរិហារកេរ្តិ៍ត្រូវមានទោស ព្រហ្មទណ្ឌតាមច្បាប់អន្តរជាតិក៏ដោយ ការរឹតត្បិតណាមួយទៅលើសេរីភាពនៃការបញ្ចេញមតិ គប្បីធ្វើឡើងអោយស្របច្បាប់ (តាមច្បាប់ក្នុងស្រុក) មានលក្ខណៈចាំបាច់ និងសមហេតុសមផល[១០] ។ តាមយោបល់របស់លីកាដូ ប្រសិនបើការរឹតត្បិតមិនជាការចាំបាច់ និងមិនសមហេតុសមផលទៅនឹងផលប្រយោជន៍សង្គមដែលទទួលបានទេនោះ ការរឹតត្បិតនោះ គឺជាការរំលោភលើសិទ្ធិសេរីភាពនៃការបញ្ចេញមិត ដូច្នេះវាជាការផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ[១១] ។ គួរអោយបារម្ភបំផុតនោះ គឺរបៀបដែលបានធ្វើអោយមានភាពមិនច្បាស់លាស់នូវទំនាក់ទំនងរវាងអំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ដើម្បីបំបាត់សម្លេង និងដាក់ពន្ធនាគារអ្នករិះគន់ ។ នៅក្នុងសន្ទរកថាមួយដែលផ្សាយនៅថ្ងៃទី១៧ ខែតុលា សម្តេចនាយរដ្ឋមន្ត្រីបានបញ្ចេញប្រតិកម្មតបយ៉ាងខ្លាំងៈ "ការអត់ធ្មត់របស់ខ្ញុំដល់កំណត់ហើយ ។ ក្នុងករណីណាមួយនោះ ការ បាត់បង់សេចក្តីអត់ធ្មត់របស់ខ្ញុំនឹងធ្វើទៅតាមច្បាប់ ។ ប្រសិនបើខ្ញុំ មិនធ្វើតាម

---

[៧] ការចោទប្រកាន់ក៏ត្រូវបានធ្វើឡើងប្រឆាំងទៅនឹងអ្នកទាំងបីទៀត ដែលទាំងអស់គ្នាបានស្វែងរកលាក់ខ្លួននៅក្រៅប្រទេស ។ របាយការណ៍សង្ខេបរបស់ LICADHO ដែលមានចំណងជើងថា : កម្ពុជា : ការវាយប្រហារទៅលើសេរីភាពបញ្ចេញមតិ និងសិទ្ធិនយោបាយ ថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ ។

[៨] សេចក្តីប្រកាសព័ត៌មានរបស់អង្គការសហប្រជាជាតិ ធ្វើឡើងដោយលោក ភីតឺ ឡឺប្រិច (Peter Leuprecht) តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥ ។ អ្នកទាំងពីរត្រូវចាប់ខ្លួនតាមដីកាចេញដោយតុលាការក្រុងភ្នំពេញ ។ ដីកាបែបនេះអាចចេញ ដោយស្របច្បាប់ នៅពេលជនជាប់ចោទខកខានមិនបានបង្ហាញខ្លួនចំពោះតុលាការក្រោយពីបានទទួលដីកាកោះត្រឹមត្រូវប៉ុណ្ណោះ ដែលករណីនេះ មិនបានកើតឡើងដូច្នេះទេ ។ តាមច្បាប់កម្ពុជាការចោទប្រកាន់ពីបទញុះញង់ ត្រូវតែមានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មជាក់ស្តែង ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ។ បុរសនេះ មិនបានញុះញង់អោយ មានឧក្រិដ្ឋកម្មណាមួយទេ ហើយមិនត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តិដូច្នោះឡើយ ។

[៩] មាត្រា១៧ នៃ UDHR រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៤១ ការការពារសេរីភាពបញ្ចេញមតិ និងមាត្រា៣១ មានបញ្ចូល ICCPR ។

[១០] សូមមើលបន្ថែម "គោលការណ៍ក្រុង Siracusa " អង្គការសហប្រជាជាតិ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម គោលការណ៍ក្រុង Siracusa ស្តីពីបញ្ញត្តិទាក់ទងទៅ នឹងការ រឹតត្បិត និងការដកហូតនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ U.NDocE/CN.4/1985/4,ឧបសម្ព័ន(198 អាចរកបាននៅអាសយដ្ឋាន http://www1.umn.edu/humanrts/instree/siracusaprinciples.htmlនិង"គោលការណ៍ក្រុងម៉ាឌ្រីត" របាយការណ៍ជាលាយលក្ខណ៍អក្សរដាក់ជូន ដោយគណៈកម្មការ អ្នកជំនាញច្បាប់គោលការណ៍ក្រុងម៉ាឌ្រីត ស្តីអំពីទំនាក់ទំនងរវាងឯករាជ្យភាពនៃបណ្តាញព័ត៌មាន និងតុលាការ ចេញផ្សាយនៅថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ១៩៩៤, អាចរកបាននៅអាសយដ្ឋាន http://www.unhchr.ch/ Huridocda/ Huridoca.nsf/0/ba4aa28729b3df7180256775004ec1c4?Opendocument ។

[១១] មាត្រា១៩ នៃ ICCPR រដ្ឋធម្មនុញ្ញ កម្ពុជា មាត្រា៣១ និង ៤១ ។

ច្បាប់ទេនោះ កងកម្លាំងប្រដាប់អាវុធ គឺនៅក្នុងដៃខ្ញុំ គ្មាននរណាអាចជំទាស់បានឡើយ" ។ សម្តេចនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ដោយពុំសូវលាក់លាមចំពោះអ្នករិះគន់លោកថា : "អ្នកគាំទ្រនៅពីក្រោយ ដែលខ្សឹបខ្សៀវពីរឿងផ្សេងៗ មិនថាជានរណាក៏ដោយត្រូវប្រយ័ត្ន....ខ្ញុំអាចនឹងចោទប្រកាន់អ្នកឯងបាន"[១២] ។ ប្រតិកម្មក្នុងការធ្វើអធិប្បាយនេះ និងការបែងចែកអំណាចរវាងអង្គនិតិប្រតិបត្តិនិងអំណាចតុលាទាំងនេះបានស្តែងអោយឃើញថែមទៀត ដោយទង្វើរបស់រដ្ឋាភិបាលនៅ ឆ្នាំ២០០៥ ។

ក្រោយពីការចាប់ខ្លួនលោក ម៉ម សូណង់ដូ និងលោក រ៉ុង ឈុន ដែលជាអ្នកការពារសិទ្ធិមនុស្សដ៏សំខាន់ និងនាំអោយអ្នកការពារសិទ្ធិមនុស្សផ្សេងទៀតមានការភ័យខ្លាចថាពួកគេអាចជាមុខសញ្ញាបន្ទាប់ ។ ជាថ្មីម្តងទៀត គួរអោយសោកស្តាយនោះការភ័យខ្លាចទាំងនេះក៏បានកើតមានឡើងមែននៅខែធ្នូ នៅពេលរដ្ឋាភិបាលបានធ្វើការចោទប្រកាន់ប្រឆាំងនឹងសកម្មជនសិទ្ធិមនុស្ស គឺលោក កឹម សុខា លោក ប៉ា ងួនទៀង និងលោក យេង វីរៈ ដែលករណីអ្នកទាំងនេះមាននិយាយលំអិតនៅក្នុងផ្នែកទី III (ខាងក្រោមនេះ) ។

## ការបដិសេធនៃសិទ្ធិជួបប្រជុំដោយសន្តិវិធី

សិទ្ធិធ្វើបាតុកម្មដោយសន្តិវិធី និងការប្រមូលផ្តុំដោយសន្តិវិធី ត្រូវបានការពារដោយច្បាប់អន្តរជាតិ[១៣] និងដោយរដ្ឋធម្មនុញ្ញកម្ពុជា[១៤] ហើយសិទ្ធិទាំងនេះ គឺជាមូលដ្ឋានគ្រឹះសំរាប់ដំណើរការលទ្ធិប្រជាធិបតេយ្យ ។ ប៉ុន្តែ ចាប់តាំងពីមាន "កុប្បកម្មប្រឆាំងថៃ" នៅខែមករា ឆ្នាំ២០០៣មក រដ្ឋាភិបាលបានប្រើប្រាស់បទពិសោធន៍អវិជ្ជមានរបស់ខ្លួន ក្នុងការចាត់វិធានការប្រកបដោយប្រសិទ្ធភាព ធ្វើជាលេសដើម្បីបង្ក្រាបច្រើនលើកច្រើនសារទៅលើការប្រមូលផ្តុំ និងបាតុកម្មដោយសន្តិវិធី ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ អង្គការមិនមែនរដ្ឋាភិបាលនានា មិនត្រូវបានអនុញ្ញាតអោយដង្ហែជាក្បួន និងប្រមូលផ្តុំតវ៉ាទាក់ទងនឹងបញ្ហានានា ដូចជាទិវាបរិស្ថានពិភពលោក ទិវានារីអន្តរជាតិ អំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ សិទ្ធិការងារ និងសេរីភាពប្រជាពលរដ្ឋជាដើម។ ក្រុមឯកជនក៏ប្រឈមមុខនឹងការរឹតត្បិត ការបំភិតបំភ័យ និងអំពើហិង្សាដែរនៅពេលព្យាយាម ប្រើប្រាស់សិទ្ធិប្រមូលផ្តុំដោយសន្តិវិធីរបស់ខ្លួន[១៥] ។

តាមច្បាប់អន្តរជាតិ ការរឹតត្បិតសិទ្ធិជួបជុំដោយសន្តិវិធី ត្រូវតែស្របនឹងច្បាប់ក្នុងស្រុកមានលក្ខណៈចាំបាច់ និងសមហេតសមផល ។ ទោះជាយ៉ាងណាក៏ដោយ តំណាងរដ្ឋាភិបាលនៅតែបន្តលើកពីការព្រួយបារម្ភផ្នែកសន្តិសុខ ដើម្បីជាហេតុផលនៃការរារាំង និងការរំខានដល់ការប្រមូលផ្តុំជាសាធារណៈ ។ សូម្បីតែប្រមូលផ្តុំដោយសន្តិវិធីជាក្រុមតូចៗរបស់ប្រជាពលរដ្ឋ ក៏ត្រូវ

---

[១២] សន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រី នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៥ ការពិនិត្យតាមដានរបស់ BBC ទៅលើទូរទស្សន៍ កម្ពុជា នៅភ្នំពេញ កម្ពុជា 0500 GMT

[១៣] មាត្រា២១ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ។

[១៤] មាត្រា៣៧ និង៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ការពារសិទ្ធិបាតុកម្ម និងប្រមូលផ្តុំដោយសន្តិវិធី ។ មាត្រា៣១ មានបញ្ចូលកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ និងសេចក្តីប្រកាសសកលស្តីពីសិទ្ធិមនុស្ស ។

[១៥] របាយការណ៍សង្ខេបរបស់លីកាដូ ស្តីពី "ការរឹតត្បិតលើសេរីភាពប្រមូលផ្តុំនៅកម្ពុជា" ចេញផ្សាយខែធ្នូ ឆ្នាំ២០០៥ ។ "ការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៤ ចេញផ្សាយខែធ្នូ ឆ្នាំ២០០៤ ។ គណៈកម្មការប្រព្រឹត្តិកម្មសិទ្ធិមនុស្សកម្ពុជា Cambodian Human Rights Action Committee-CHRAC) "ការបង្ក្រាប ទៅលើការប្រមូលផ្តុំ និងបាតុកម្មដោយអាជ្ញាធរក្រុងភ្នំពេញ តាំងពីខែមករា ឆ្នាំ២០០៣" ចេញផ្សាយខែវិច្ឆិកា ឆ្នាំ២០០៤ ។ អាចរកបាននៅអាសយដ្ឋាន http://www.licadho.org/

បានបដិសេធមិនអនុញ្ញាតអោយធ្វើ ឬក៏ត្រូវបានបំបែកដោយអាជ្ញាធរ ជួនកាលទទួលរងការប្រើអំពើហិង្សាទៀតផង ។ លីកាដូ ជឿជាក់ថា វិធានការបែបនេះមិនមែនជាការចាំបាច់ និងមិនសមហេតុសមផលឡើយ ហើយជាការរំលោភរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់ អន្តរជាតិទៀតផង ។

ឆ្លងកាត់ឆ្នាំ២០០៥ នគរបាលបានធ្វើអន្តរាគមន៍ ដើម្បីរារាំង ឬបំបែកការប្រមូលផ្តុំបាតុកម្ម ការដង្ហែក្បួនវេទិកាពិភាក្សាសាធារណៈ បាតុកម្មរបស់កម្មករ ការតវ៉ាអំពីទំនាស់ដីធ្លីជាង ៤០ ករណី ។ អំពើហិង្សា និងការបំភិតបំភ័យត្រូវបានប្រើប្រាស់ជារឿយៗ។ នៅថ្ងៃទី ៧ ខែមករា ឆ្នាំ២០០៥ នគរបាលបានវាយបាតុករដោយស្វ័យកាំភ្លើង នឹងដំបង នឹងបានប្រើដំបងឆក់ ។ នៅថ្ងៃទី១១ ខែកុម្ភៈ អាជ្ញាធរបានហាមឃាត់សកម្មជនអង្គការសិទ្ធិមនុស្ស UNCOHCHR និងអ្នកយកព័ត៌មានឯករាជ្យមិនអោយទៅជួបបាតុករ ដែលត្រូវចាប់ខ្លួននៅថ្ងៃនោះទេ ។ មានតែអ្នកសារព័ត៌មានធ្វើការអោយស្ថានីយ៍ទូរទស្សន៍ CTN និងទូរទស្សន៍ប៉ុស្តិ៍លេខ៣ ដែលគាំទ្ររដ្ឋាភិបាលប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតអោយចូលការិយាល័យនគរបាលស្រុក ។ នៅថ្ងៃទី ២៨ ខែមិនា នគរបាលនគរបាលបានសំរុកចូលការិយាល័យចលនានិស្សិត ដើម្បីលទ្ធិប្រជាធិបតេយ្យ ដើម្បីរារាំងកុំអោយនិស្សិតធ្វើបាតុកម្ម នគរបាលបានរារាំងអ្នកសារព័ត៌មាន និងបុគ្គលិកសិទ្ធិមនុស្ស រួមទាំងចំពោះជនណាដែលព្យាយាមតាមដានព្រឹត្តិការណ៍នោះ ។ នៅថ្ងៃទី ២៧ ខែកញ្ញា សមាជិកចលនានិស្សិត ដើម្បីលទ្ធិប្រជាធិប្បតេយ្យត្រូវបានគេចាប់ខ្លួននៅក្រៅការិយាល័យដោយសារតែព្យាយាមធ្វើបាតុកម្មដោយសន្តិវិធី[១៦] ។

ចំពោះមុខការបំភិតបំភ័យបែបនេះ អ្នកការពារសិទ្ធិមនុស្សមានការភ័យខ្លាចំពោះអំពើហិង្សា និងការចាប់ខ្លួននៅពេលរៀបចំព្រឹត្តិការណ៍សាធារណៈ ដើម្បីផ្សព្វផ្សាយអំពីបញ្ហាសិទ្ធិមនុស្ស ឬនៅពេលត្រួតពិនិត្យបាតុកម្មរៀបចំឡើង ដោយអ្នកដទៃទៀត ដោយបដិសេធន៍មិនអនុញ្ញាតអោយរៀបចំព្រឹត្តិការណ៍ទាំងនេះ ដោយហេតុផលមិនត្រឹមត្រូវថា ព្រឹត្តិការណ៍ទាំងនេះបង្កការគំរាមកំហែងដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ អាជ្ញាធរបានរំខានដល់សកម្មភាព ដែលចាំបាច់សំរាប់លទ្ធិប្រជាធិបតេយ្យ និងការការពារសិទ្ធិមនុស្ស ។ ប្រជាពលរដ្ឋកម្ពុជាមានសិទ្ធិលើកកំពស់ការយល់ដឹងអំពីបញ្ហាសិទ្ធិមនុស្ស និងជំរុញអោយរដ្ឋាភិបាល និងសហគមន៍ធ្វើសកម្មភាពផ្សេងៗ ។ បូកផ្សំជាមួយនឹងឥទ្ធិពលនៃការកាត់ទោសពីបទបរិហារកេរ្តិ៍ ការរឹតត្បិតសេរីភាពក្នុងការជួបប្រជុំគ្នា ដូច្នេះ បានធ្វើអោយប៉ះពាល់ដល់កិច្ចប្រឹងប្រែងនៃកិច្ចការពារសិទ្ធិមនុស្សរបស់សង្គមស៊ីវិល ។

## ទំនាស់ដីធ្លី

ទោះបីជាមានកំណើនប្រជាពលរដ្ឋនៅតាមជនបទ និងតំរូវការដីធ្លីកាន់តែខ្លាំងឡើងក៏ដោយ ក៏នៅពេលថ្មីៗនេះ រដ្ឋាភិបាល បានអនុវត្តគោលនយោបាយផ្តល់ដីសម្បទានសេដ្ឋកិច្ចធំៗដល់ក្រុមហ៊ុននានា ដែលជារឿយៗត្រូវបានគេប្រើជាលេសដើម្បីបិទបាំងការ កាប់ឈើខុសច្បាប់ ។ ទោះបីច្បាប់ភូមិបាលឆ្នាំ២០០១ ចែងពីទំហំអតិបរមានៃដីសម្បទានត្រឹមតែ ១០,០០០

---

[១៦] របាយការណ៍សង្ខេបរបស់អង្គការលីកាដូ : "ការរឹតត្បិតលើសេរីភាពក្នុងការប្រមូលផ្តុំ នៅកម្ពុជា" ចេញផ្សាយខែធ្នូ ឆ្នាំ ២០០៥ .

ហិកតាក៏ដោយ[១៧] ក៏ទំហំដីសម្បទានធំៗខ្លះមានទំហំធំជាងនេះរហូតដល់ទៅ ៣០ ដង ។ ក្នុងករណីខ្លះ ដីសម្បទានអាជីវកម្មតែមួយកន្លែងមានទំហំធំជាងពាក់កណ្តាលនៃទំហំខេត្តខ្លះទៀតផង[១៨] ។ កង្វះតម្លាភាពជុំវិញការផ្តល់កម្មសិទ្ធិនិងការផ្តល់សម្បទានដោយលាក់កំបាំងបានបិទច្រកដល់ការពិភាក្សាដែលត្រូវផ្តល់ព័ត៌មានគ្រប់គ្រាន់ និងផ្តល់ជាបរិយាកាសមួយងាយស្រួលដល់អំពើពុករលួយ[១៩] ។ ការអំពាវនាវពីអន្តរជាតិអោយបើកបង្ហាញជាបន្ទាន់អំពីព័ត៌មានសម្បទានដីធ្លីត្រូវបានរដ្ឋាភិបាលកម្ពុជាធ្វើមិនដឹងធ្វើមិនឮជារៀងរហូត ។

ទំនាក់ទំនងដ៏ជិតស្និទ្ធរវាងក្រុមហ៊ុនសម្បទាន និងមន្ត្រីរដ្ឋាភិបាលខ្លះដែលមានឥទ្ធិពល និងការបានផលកម្រៃយ៉ាងក្រាស់ក្រែលពីការគ្រប់គ្រងសម្បទាន នាំអោយអង្គការមិនមែនរដ្ឋាភិបាល ឬក្រុមដែលទាមទារអោយមានកំណែទម្រង់ ឬធ្វើការស៊ើបអង្កេតត្រូវប្រឈមមុខនឹងហានិភ័យយ៉ាងធ្ងន់ធ្ងរ ។ អំពើហិង្សា និងការគំរាមកំហែង ត្រូវបានគេប្រើប្រាស់ជាញឹកញាប់ ។ នៅខែកក្កដា អ្នកគ្រប់គ្រងប្រតិបត្តិការកាប់ឈើខុសច្បាប់នៅខេត្តកំពង់ធំ បានគំរាមកំហែង និងបាញ់សមាជិកសហគមន៍ព្រៃឈើពីរនាក់ ។

ការបាញ់នោះ គឺជាការឆ្លើយតបចំពោះការព្យាយាមរបស់សមាជិកសហគមន៍ ក្នុង ការបញ្ឈប់អ្នកកាប់ឈើខុសច្បាប់កុំអោយកាប់ដើមឈើផ្តល់ជ័រ ដែលត្រូវបានការ


អ្នកដឹកនាំសហគមន៍ក្នុងខេត្តពោធិសាត់ ប្រតិកម្មចំពោះសេចក្តីជូនដំណឹងអំពីការបណ្តេញចេញ

ពារនៅក្បែរចំការកៅស៊ូសម្បទានមួយកន្លែង ។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងអ្នកដឹកនាំសហគមន៍បានរងការគំរាមកំហែង ក្រោយពីមានបាតុកម្មនៅខែមិថុនា និងខែកក្កដា ដោយជនជាតិភ្នងដែល ជាម្ចាស់ស្រុក ដែលរងគ្រោះដោយសម្បទានដីទៅអោយ ក្រុមហ៊ុនវូស៊ីស្សាន (Wuzhishan) នៅខេត្តមណ្ឌលគិរី ។ ជាងនេះទៅទៀត អាជ្ញាធរមូលដ្ឋានបានដាក់ការរឹតត្បិតទៅលើការងារ របស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិដែលកំពុងតែធ្វើការនៅក្នុងខេត្តនេះទៀតផង[២០] ។ នៅខេត្តរតនៈគិរី អ្នកសំរបសំរួលអង្គការ ADHOC ត្រូវប្រឈមុខនឹងបណ្តឹងពីបទផ្តល់ព័ត៌មានមិនពិតក្រោយពីបានផ្តល់កិច្ចសម្ភាសន៍មួយនៅខែកញ្ញា ដល់វិទ្យុអាស៊ីសេរីអំពីអន្តរាគមន៍របស់គាត់ចំពោះទំនាស់ដីធ្លីរវាងគ្រួសារជនជាតិដើម និងមន្ត្រីយោធាម្នាក់ ។ នៅពេលសរសេររបាយការណ៍នេះ ករណីនេះមិនទាន់ចប់នៅឡើយទេ[២១] ។

---

[១៧] ច្បាប់ភូមិបាល កម្ពុជា ឆ្នាំ២០០១ មាត្រា ៥៩ ។

[១៨] របាយការណ៍របស់តំណាងពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ចេញផ្សាយ ថ្ងៃទី១៩ ខែធ្នូ ២០០៣ ។

[១៩] Ibid. .

[២០] ព័ត៌មានទទួលបានពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា និងបទសម្ភាសន៍ជាមួយអ្នកការពារសិទ្ធិមនុស្ស នៅអង្គការ ADHOC

[២១] Ibid

នៅខែវិច្ឆិកា ទាហានបានបាញ់អ្នកភូមិនៅខេត្តបាត់ដំបង ដែលព្យាយាមការពារតំណាងម្នាក់នៅក្នុងទំនាស់ដីធ្លីពីការចាប់ខ្លួនដោយខុសច្បាប់ ។ ទំនាស់ដីធ្លីនេះ ពាក់ព័ន្ធនឹងដីធ្លីរាប់ម៉ឺនហិកតា និងមានការជំទាស់ពីប្រជាពលរដ្ឋចំនួន ១,៦០០ គ្រួសារ ។ អ្នកភូមិក៏ត្រូវរារាំងមិនអោយទៅសួរសុខទុក្ខតំណាងម្នាក់ទៀត ដែលត្រូវបានចាប់ខ្លួនដោយខុសច្បាប់កាលពីមួយសប្តាហ៍មុននោះ ។ អ្នកភូមិជាច្រើនត្រូវរងរបួសដោយខ្លះរងរបួសធ្ងន់ធ្ងរ ។ មានប្រជាពលរដ្ឋម្នាក់តម្រូវអោយកាត់ម្រាមដៃ ។

នៅខែធ្នូ ឆ្នាំ២០០៥ សម្តេចនាយករដ្ឋមន្ត្រីបានប្រាប់មន្ត្រីរដ្ឋាភិបាល អាជីវករ និងទាហានអោយឈប់ទន្ទ្រានវាតដីព្រៃ និងទ្រព្យសម្បត្តិឯកជន ។ សម្តេចមានប្រសាសន៍ថា "ខ្ញុំសូមព្រមានថា ប្រសិនបើនៅតែបន្តដណ្តើមដីទៀត នឹងមានបដិវត្តន៍កសិករជាពុំខាន ... ដល់ពេលដែលត្រូវបញ្ឈប់ហើយ មុនពេលប្រជាពលរដ្ឋបាត់បង់ការអត់ធ្មត់"[២២] ។ គេកំពុងតែរង់ចាំមើលថាតើសម្តេចនាយករដ្ឋមន្ត្រីនឹងតាមដានគោលនយោបាយគ្មានការអនុគ្រោះរបស់លោកចំពោះការដណ្តើមកាន់កាប់ដី និងការរំលោភសិទ្ធិមនុស្ស ដែលកើតមានជាមួយនឹងការដណ្តើមកាន់កាប់ដីនោះឬយ៉ាងណា?-សំរាប់ពេលនេះ ការដោះស្រាយបញ្ហា អំពើហិង្សានៅតែជាបញ្ហាដ៏ធ្ងន់ធ្ងរបំផុត ដែលអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាត្រូវតែប្រឈមមុខ ។

## ការបង្ហាញជាសាធារណៈនូវអ្នកការពារសិទ្ធិមនុស្ស

នៅអំឡុងឆ្នាំ២០០៥ ជាញឹកញាប់ អ្នកការពារសិទ្ធិមនុស្ស គឺជាប្រធានបទនៃការវាយប្រហារដោយពាក្យសម្តី និងការបង្ហាញអោយយល់ខុស ចំពោះអ្នកការពារសិទ្ធិមនុស្សពីសំណាក់មន្ត្រីរដ្ឋាភិបាលខ្លះ ជាពិសេសនៅអំឡុងពេលថ្លែងសន្ទរកថា ដែលបានផ្សព្វផ្សាយតាមទូរទស្សន៍ និងវិទ្យុជាតិ ដែលគាំទ្ររដ្ឋាភិបាល ។

មានឧទាហរណ៍ជាច្រើនផ្សេងទៀត។ នៅអំឡុងពេលថ្លែងសន្ទរកថាដ៏វែងនៅពិធីមួយនៅខេត្តកណ្តាលដែលត្រូវបានចាក់ផ្សាយតាមទូរទស្សន៍កាលពីខែមករា សម្តេចនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា ក្រុមសិទ្ធិមនុស្សជាអ្នកការពារចោរប្លន់ និងចោរលួច[២៣] ។ នៅក្នុងឱកាសនោះ សម្តេចនាយករដ្ឋមន្ត្រីមានប្រសាសន៍ដៀមដាមទៅកាន់អ្នកដឹកនាំសង្គមស៊ីវិលម្នាក់ដែលលោកបានអោយងារថា "អាគុកសុរា" ដែលគេជឿជាក់ថាប្រហែលជាសំដៅទៅរក លោក កឹម សុខា នាយកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា[២៤] ។ នៅពេលក្រោយមកទៀតក្នុងខែដដែលនោះ រថយន្តដែលដឹកអ្នកចូលរួមពីវេទិកាសាធារណៈរបស់មជ្ឈមណ្ឌលសិទ្ធិកម្ពុជាត្រូវនគរបាលបញ្ឈប់ និងឆែកឆេរដោយអះអាងថា ពួកគេឆែកឆេររកអាវុធ ។

នៅខែមិថុនា ប្រមុខរដ្ឋាភិបាលបានព្រមានចំពោះវេទិកាសាធារណៈមួយដោយមិនបញ្ចេញឈ្មោះដែលបានរិះគន់លោក[២៥] ។

---

[២២] វង់ សុខេង "ពាក្យព្រមានរបស់លោកនាយកមន្ត្រី : ចូរបញ្ឈប់ការលួចដី" កាសែតភ្នំពេញប៉ុស្តិ៍ លេខ ១៤/២៥ ថ្ងៃទី១៦-២៩ ខែធ្នូ ឆ្នាំ២០០៥ ។

[២៣] កាសែតកម្ពុជាថ្មី ថ្ងៃទី០៩-១០ ខែមករា ឆ្នាំ២០០៥ បកប្រែនៅក្នុងកាសែត The Mirror នៅថ្ងៃទី០៩-១៥ ខែមករា ឆ្នាំ២០០៥ ។

[២៤] ព្រឹត្តិបត្រសារព័ត៌មាន The Cambodia Daily ចេញផ្សាយថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៥ ។

[២៥] ព្រឹត្តិបត្រសារព័ត៌មាន The Cambodia Daily ចេញផ្សាយថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៥ ។

ពីរខែក្រោយមក វេទិកាមួយចំនួនដែលរៀបចំដោយ CCHR ត្រូវបានរំខាន ហើយក្នុងករណីមួយនោះ ត្រូវបិទដោយអាជ្ញាធរមូលដ្ឋាន ។សេចក្តីថ្លែងមួយនៅខែតុលា សម្តេចនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា "វេទិកាប្រជាធិបតេយ្យសិទ្ធិមនុស្ស និងវេទិកាបែបនេះឯទៀត វាមិនធ្វើអោយភាពក្រីក្រហោះចេញពីយើងទេ ។ ការស្តាប់រឿងដូច្នេះ គឺជាការខាតបង់ពេលវេលា"[២៦] ។

បុគ្គលិកអង្គការសិទ្ធិមនុស្សអន្តរជាតិ គឺទទួលរងការរំលោភដោយពាក្យសម្តី និងការចោទប្រកាន់គ្មានមូលដ្ឋាន ។ នៅខែកុម្ភៈ ឯ. ឧ. ឱម យិនទៀង ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាល និងជាទីប្រឹក្សាសម្តេចនាយកបានវាយប្រហារជាសាធារណៈចំពោះលោក ភីតឺ ឡឺប្រិច (Peter Leuprecht) ដែលពេលនោះជាតំណាងពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ។ ឯ. ឧ. យិនទៀង ថ្លែងថារបាយការណ៍ធ្វើឡើងដោយលោក ឡឺប្រិច ហាក់ដូចជាធ្វើជាមិនដឹងមិនឮអំពីរដ្ឋធម្មនុញ្ញកម្ពុជា ដោយអះអាងថាតំណាងពិសេសរូបនេះចាត់ទុកខ្លួនឯង "ធំជាងតុលាការ" [២៧] ។

ក្រោយពីដំណើរទស្សនកិច្ចមកកម្ពុជា នៅខែសីហារបស់លោកមីលូន កូតារី (Miloon Kothariz) តំណាងពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិលំនៅដ្ឋាន សម្តេចនាយកដ្ឋមន្ត្រីមានប្រសាសន៍ថា "មានមនុស្សម្នាក់នោះជាតំណាងអង្គការសហប្រជាជាតិ .... គេមក (កម្ពុជា) ដើម្បីតែលុយប៉ុណ្ណោះ ។ គេចាត់ទុកប្រជាពលរដ្ឋកម្ពុជាជាចោរ[២៨] ។" គួរកត់សម្គាល់ថា តំណាងពិសេសអង្គការសហប្រជាជាតិ ដូចជាលោក កូតារី ដែលតែងតែរិះគន់អំពីការដណ្តើមកាន់កាប់ដី និងការផ្ទេរដីរដ្ឋដោយលាក់កំបាំងដល់ក្រុមហ៊ុនឯកជននៅកម្ពុជា ដោយបានមិនទទួលប្រាក់បៀវត្សរ៍សំរាប់កិច្ចប្រឹងប្រែងការពារសិទ្ធិមនុស្សឡើយ។ រយៈពីរ សប្តាហ៍ក្រោយមកទៀត ឯ. ឧ. ប្រាក់ សុខុន ទីប្រឹក្សាសម្តេចនាយកបានអះអាងថា សម្តេចនាយករដ្ឋមន្ត្រីបានរិះគន់ការិយាល័យអង្គការសហប្រជាជាតិនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅពេលមានកិច្ចប្រជុំអាស៊ាន-អង្គការសហប្រជាជាតិ ដែលតាមរបាយការណ៍បានថ្លែងថា "ប្រសិនបើពួកគេរាយការណ៍ល្អអំពីសិទ្ធិមនុស្ស ធ្វើអោយពួកគេគ្មានការងារធ្វើ"[២៩] ។

ការបង្ហាញជារបៀបអរិជ្ជមានទាំងនេះ មិនមែនមានត្រឹមតែពាក្យសម្តីទេ ។ នៅខែតុលា ស្ថានីយ៍ទូរទស្សន៍បាយ័ន ដែលគាំទ្ររដ្ឋាភិបាលបានចាប់ផ្តើមផ្សាយកម្មវិធីដែលមានចំណងជើងថា *"អាងសិទ្ធិប្រយ័ត្ន"* ("Overuse Your Rights, Be Careful") ដែលរៀបរាប់បែបឆាកថ្លុកកំប្លែងអំពីអំពើហិង្សាប្រឆាំង នឹងអ្នកការពារសិទ្ធិ ។ វគ្គទីមួយនៃរឿងនេះបង្ហាញពីលោក អ៊ូ ប៊ុណ្ណារ៉ាត់ ជាអ្នកកំប្លែងដ៏ល្បីម្នាក់ ដើរតួជាសកម្មជនម្នាក់អប់រំអ្នកភូមិពីសិទ្ធិរបស់ពួកគេ ។ ទោះជាយ៉ាងណាក៏ដោយ ការបង្រៀនរបស់គាត់នាំអោយមានការរំខាននៅក្នុងសហគមន៍ និងបង្កអោយមានការបះបោរ គាត់ក៏ត្រូវប្រជាពលរដ្ឋវាយ ។ ជាការបកស្រាយកម្មវិធីនេះ លោក ប៊ុណ្ណារ៉ាត់ បានពន្យល់ថា "ប្រទេសរបស់យើង មិនដូចជាប្រទេសដទៃទៀតទេ ។ នៅប្រទេសអឺរ៉ុប គេមិនវាយកូនគេទេ ប៉ុន្តែ នៅកម្ពុជាក្មេងៗត្រូវគោរពចាស់ទុំរបស់ខ្លួន"[៣០] ។

---

[២៦] ព្រឹត្តិបត្រសារព័ត៌មាន The Cambodia Daily ចេញផ្សាយថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៥ ។

[២៧] ការពិនិត្យឡើងវិញនូវព័ត៌មានរបស់ព្រឹត្តិបត្រសារព័ត៌មាន The Cambodia Daily ចេញផ្សាយថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៥ ។

[២៨] ព្រឹត្តិបត្រសារព័ត៌មាន The Cambodia Daily ចេញផ្សាយថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ ។

[២៩] ព្រឹត្តិបត្រសារព័ត៌មាន The Cambodia Daily ចេញផ្សាយថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៥ ។

[៣០] ពីត្តិបត្រសារព័ត៌មាន The Cambodia Daily ចេញផ្សាយថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ ។

ដូចអ្នកឯទៀត ដោយរាប់បញ្ចូលទាំងអ្នកនយោបាយផងដែរ អ្នកការពារសិទ្ធិមនុស្សមិនអាចរួចផុតពីការប្រឆាំងរិះគន់ ឬចំអកនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ការបង្ហាញជាអរិជ្ជមាន និងទង្វើមិនសមស្របដោយអ្នកបំរើការរដ្ឋ និងអ្នកគាំទ្ររបស់ខ្លួន ដែលនាំអោយគេមិនសូវមានទំនុកចិត្តចំពោះការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះការគោរពសិទ្ធិមនុស្ស ឬការការពារអ្នកតស៊ូមតិ ដើម្បីសិទ្ធិមនុស្សនៅកម្ពុជា ។

# III. ការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សនៅឆ្នាំ២០០៥

ព្រឹត្តិការណ៍នៅឆ្នាំ២០០៥ បង្ហាញអោយឃើញនូវលំនាំដ៏ស៊ីសង្វាក់គ្នានៃការបំភិតបំភ័យ ការគំរាមកំហែង និងការយាយី ប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ។ ហេតុការណ៍នេះ នាំអោយមានការបារម្ភយ៉ាងខ្លាំង អំពីសុវត្ថិភាព និងនិរន្តរភាពនៃការតាមដាន និងការតស៊ូមតិអំពីសិទ្ធិមនុស្ស ដែលមានផលប៉ះពាល់យ៉ាងទូលំទូលាយ សំរាប់ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យជាចំហ និងនីតិរដ្ឋ ។ អ្នកដែលអាចប្រព្រឹត្តមិនគប្បីនេះ គេអាចមើលឃើញខ្លះពីក្នុងចំណោមបុគ្គលឯកជន រហូតដល់មន្ត្រីនគរបាល មន្ត្រីយោធា មេឃុំ មន្ត្រីមន្ទីរខេត្ត មន្ត្រីនាយកដ្ឋានក្រុង មន្ត្រីសុយោដីស្រុក អភិបាលស្រុក មន្ត្រីតុលាការ និងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់មួយចំនួន។

ប្រភេទនៃការបំភិតបំភ័យរួមមាន អំពើហិង្សាលើរូបរាងកាយ ការគំរាមកំហែង វិធានការច្បាប់ ការចាប់ខ្លួន ការឃុំខ្លួន និងការដាក់កំហិតលើការធ្វើដំណើរជាដើម ។ ជាទូទៅ ឧបទ្ទវហេតុនៃអំពើហិង្សាដោយផ្ទាល់ប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្សបានថយចុះ (លើកលែងតែចំពោះអ្នកដែលពាក់ព័ន្ធនឹងការតវ៉ាជាសាធារណៈ) ផ្ទុយទៅវិញ ជនល្មើសបានផ្តោតទៅលើការបំភិតបំភ័យ ការបង្កជាឧបសគ្គ និងការប្រឈមមុខតាមផ្លូវច្បាប់វិញ ។ ទោះជាយ៉ាងណាក៏ដោយ គោលបំណង គឺនៅដដែល គឺ : បំបាក់ទឹកចិត្តប្រជាពលរដ្ឋមិនអោយការពារសិទ្ធិរបស់ខ្លួន និងអ្នកដទៃ ។

បញ្ជីឧបទ្ទវហេតុទាក់ទងនឹងអ្នកការពារសិទ្ធិមនុស្សនៅឆ្នាំ២០០៥ មានបញ្ចូលជាឧបសម្ព័ន្ធនៅចុងបញ្ចប់នៃរបាយការណ៍នេះ ប៉ុន្តែ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបនៃករណីទាំងនេះ ។

## អំពើហិង្សា និងអំពើមនុស្សឃាត

ពុំមានរបាយការណ៍អំពីការសម្លាប់អ្នកការពារសិទ្ធិមនុស្សនៅឆ្នាំ២០០៥ទេ ប៉ុន្តែមានឧបទ្ទវហេតុហិង្សាជាច្រើនបានកើតមានឡើង ។

នៅខែកក្កដា អ្នកគ្រប់គ្រងប្រតិបត្តិការកាប់ឈើខុសច្បាប់ម្នាក់បានបាញ់សមាជិកសហគមន៍ព្រៃឈើពីរនាក់នៅខេត្តកំពង់ធំ ។ នៅក្នុងខែដដែលនោះ មាននគរបាលម្នាក់ត្រូវគេបាញ់សម្លាប់ នៅពេលកំពុងចាប់ជនពីរនាក់ ដែលត្រូវបានសង្ស័យថាប៉ុនប៉ងសម្លាប់អ្នកដឹកនាំសហគមន៍នៅខេត្តរតនៈគិរី ដែលបានទទួលការគំរាមកំហែងច្រើនលើក ។ ជនសង្ស័យនោះ ក៏ត្រូវបានគេបាញ់សម្លាប់ផងដែរ ។ នៅខែវិច្ឆិកា មានអ្នកភូមិជាច្រើនត្រូវបានគេបាញ់ និងរងរបួសនៅឯការតវ៉ារឿងដីធ្លីមួយនៅខេត្តបាត់ដំបង ដែលព្យាយាមការពារតំណាងរបស់ខ្លួនពីការចាប់ខ្លួនដោយខុសច្បាប់ ។

## ការគំរាមកំហែង ការបំភិតបំភ័យ និងយាយី



នគរបាលគ្មានសណ្តាប់ធ្នាប់ ជាញឹកញាប់ត្រូវបានគេប្រើ ដើម្បីបំភិតបំភ័យសហគមន៍ដែលរងគ្រោះ

ការគំរាមកំហែងដោយពាក្យសម្តី និងការគំរាមកំហែងជាលាយលក្ខណ៍អក្សរ រួមទាំងការគំរាមកំហែងតាមទូរស័ព្ទ នៅតែជាទម្រង់នៃការបំភិតភ័យ ដែលកើតមានឡើងជាប្រចាំ ។ អ្នកបំរើការក្នុងវិស័យសិទ្ធិមនុស្ស តែងតែទទួលការគំរាមកំហែងទាំងនេះជាញឹកញាប់ នៅពេលប្រឈមមុខជាមួយមន្ត្រីសាធារណៈ ឬនគរបាលនៅពេលអ្នកទាំងនោះ បំពេញប្រតិបត្តិការរបស់ខ្លួន ។

នៅខែកក្កដា អ្នកស៊ើបអង្កេតនៃការិយាល័យអង្គការសិទ្ធិមនុស្ស, CCHR, ADHOC និង LICADHO ប្រចាំនៅខេត្តពោធិ៍សាត់ ត្រូវគេរារាំងមិនអោយថតរូបនៃការបំផ្លាញទ្រព្យសម្បត្តិឯកជននៅស្រុកភ្នំក្រវាញ ។ របង និងទីធ្លាផ្ទះរបស់គ្រួសារមួយត្រូវបំផ្លាញចោលដោយគ្មានការអនុញ្ញាតពីក្រុមគ្រួសារ ដើម្បីកសាងផ្លូវថ្មីកាត់ដីនោះ ។ នគរបាល និងអាជ្ញាធរដែនដីបានគំរាមកំហែងដកហូតហ្វីល និងម៉ាស៊ីនថតរបស់បុគ្គលិកសិទ្ធិមនុស្ស និងចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ។ ទោះបីពុំមានការដកហូត ឬចាប់ខ្លួនក៏ដោយ ក៏បុគ្គលិកសិទ្ធិមនុស្សទាំងនោះត្រូវឃុំខ្លួនជាច្រើនម៉ោង និងទទួលរងនូវការបំភិតបំភ័យយ៉ាង ធ្ងន់ធ្ងរ ។

## ការរឹតត្បិតលើការងារ និងការធ្វើដំណើរ

នៅថ្ងៃទី២៩ ខែមករា វាគ្មិនវេទិកាសន្តិវិធីរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (Cambodian Centre for Human Rights-CCHR) ត្រូវគេបញ្ឈប់រថយន្ត និងឆែកឆេររកអាវុធ ។ នៅថ្ងៃទី១០ ខែសីហា នគរបាលបានបិទវេទិការបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាមួយទៀត ដែលមានប្រជាពលរដ្ឋចូលរួមប្រហែលជា ១,០០០ នាក់ ក្រោយពីមានក្រុមមនុស្សប្រហែលជា ៤០ នាក់ ចាប់ផ្តើមស្រែកពាក្យស្លោកគាំទ្ររដ្ឋាភិបាល ដែលហាក់ដូចមានការរៀបចំទុកជាស្រេច ។ នៅថ្ងៃទី២៦ និង២៩ ខែសីហា អាជ្ញាធរបានរំខាន និងព្យាយាមរារាំងកិច្ចប្រជុំពីរទៀតរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ។

នៅខែកុម្ភៈ របាយការណ៍របស់អង្គការ Global Witness ចំនួន ២,១០០ ច្បាប់ ទាក់ទងនឹងអំពើពុករលួយមានលក្ខណៈជាស្ថាប័នក្នុងឧស្សាហកម្មកាប់ឈើត្រូវរឹបអូសដោយមន្ត្រីគយនៅអាកាសដ្ឋានអន្តរជាតិភ្នំពេញ ដោយគ្មានការពន្យល់អ្វីសោះ ។ របាយការណ៍នេះ និយាយអំពីមន្ត្រីយោធា និងរដ្ឋាភិបាលជាន់ខ្ពស់ខ្លះ ដែលពាក់ព័ន្ធក្នុងការកាប់ព្រៃឈើខុសច្បាប់ ។ នៅខែកក្កដា បុគ្គលិកបរទេសម្នាក់ត្រូវបដិសេធមិនអោយចូលប្រទេសកម្ពុជា និង ៥នាក់ផ្សេងទៀតត្រូវចុះក្នុងបញ្ជីខ្មៅរបស់រដ្ឋាភិបាល ចំណែកឯប្រមុខរដ្ឋាភិបាលបានមានប្រសាសន៍ថា អង្គការមិនមែនរដ្ឋាភិបាលនេះត្រូវ "ចប់ហើយ" នៅក្នុងប្រទេសនេះ ។ អង្គការ Global Witness ជាញឹកញាប់ គឺជាមុខសញ្ញារបស់អាជ្ញាធរ ដោយសារអង្គការនេះ រិះគន់ឥតសំចៃអំពីការពាក់ព័ន្ធរបស់យោធា និងមន្ត្រីរដ្ឋាភិបាលខ្លះក្នុងអំពើពុករលួយ និងការជួញដូរឈើខុសច្បាប់ ។ ជាលទ្ធផលនៃការគំរាមកំហែងជាញឹកញាប់

ប្រឆាំងនឹងបុគ្គលិក និងការរំខានដល់ការបំពេញការងាររបស់ខ្លួននោះ អង្គការមិនមែនរដ្ឋាភិបាលនេះ ក៏បិទការិយាល័យរបស់ខ្លួនប្រចាំនៅប្រទេសកម្ពុជា នៅខែតុលា ឆ្នាំ២០០៥[៣១] ។

នៅឆ្នាំ២០០៥ អាជ្ញាធរខេត្តមណ្ឌលគិរី បានដាក់ការកំហិតលើការងាររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិដែលប្រតិបត្តការងារនៅក្នុងខេត្តនេះ ក្រោយពីមានរឿងពាក់ព័ន្ធនឹងអ្នកស្វែងរកសិទ្ធិជ្រកកោនរបស់ជនជាតិម៉ុងតាញ៉ា និងបាតុកម្មតវ៉ាប្រឆាំងនឹងការដណ្តើមកាន់កាប់ដីដ៏ធំសំបើមរួចមក ។ អង្គការមិនមែនរដ្ឋាភិបាលនីមួយៗត្រូវប្រគល់អនុស្សារណៈនៃការយោគយល់ដល់ក្រសួងដែលពាក់ព័ន្ធ ចំណែកអភិបាលខេត្តបានតម្រូវអោយអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ជួបប្រជុំជាមួយលោករៀងរាល់ ៣ ខែម្តង ដើម្បីប្រគល់របាយការណ៍សកម្មភាពរបស់ខ្លួន ។ ជាងនេះទៅទៀត អ្នកដឹកនាំសហគមន៍ទាំងអស់ត្រូវស្នើសុំការអនុញ្ញាតពីអភិបាលខេត្ត ដើម្បីចាកចេញពីខេត្ត និងចូលរួមក្នុងបញ្ហាពាក់ព័ន្ធនឹងអង្គការមិនមែនរដ្ឋាភិបាល[៣២] ។ ការរឹតត្បិតទាំងនេះ គឺជាការរំលោភយ៉ាងច្បាស់ក្រឡែតទៅលើសិទ្ធិរបស់ប្រជាពលរដ្ឋ ដែលធានាដោយរដ្ឋធម្មនុញ្ញក្នុងការធ្វើដំណើរដោយសេរី ហើយការរឹតត្បិតទាំងនេះរៀបចំឡើង ដើម្បីបំភិតបំភ័យអ្នកការពារសិទ្ធិមនុស្ស និងដើម្បីបំបាត់សម្លេងរិះគន់លើបញ្ហាដែលមានលក្ខណៈរសើប ។

## ទោសព្រហ្មទណ្ឌ វិធានការរដ្ឋប្បវេណី ការចាប់ខ្លួន និងការឃុំខ្លួនខុសច្បាប់

ទោះបីមានការយាយីក្នុងទម្រង់ធ្ងន់ធ្ងរដូចបានពណ៌នាខាងលើនេះក្តី អ្នកដែលព្យាយាមវាយប្រហារអ្នកការពារសិទ្ធិមនុស្ស កំពុងតែបែរមករកជ្រើសរើសវិធីបំភិតបំភ័យដែលមានលក្ខណៈផ្លូវច្បាប់តែសំបកក្រៅកាន់តែច្រើនខ្លាំងឡើង ។ ស្ថានការណ៍នេះ ឆ្លុះបញ្ចាំងអោយឃើញពីការវិវឌ្ឍខ្លះឆ្ពោះទៅរកការពង្រឹងនីតិរដ្ឋ និងការយល់កាន់តែច្រើនរបស់សាធារណជនអំពីសិទ្ធិមនុស្ស ។ ម្យ៉ាងទៀត វាបង្ហាញអោយឃើញថា ជនប្រព្រឹត្តបទល្មើសកាន់តែមានវិធីសាស្ត្រកាន់តែមានភាពជឿនលឿន ។ ការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ជាបទព្រហ្មទណ្ឌ ទោះបីធ្វើឡើងដោយពិតប្រាកដ ឬជាការគំរាមកំហែង គឺជាឧបករណ៍ដែលគេចូលចិត្តយកមកប្រើប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស ដោយជនមានអំណាច ដែលស្ទើរតែមានការធានាទាំងស្រុងថា នឹងបានឈ្នះនៅក្នុងតុលាការ ដែលភាគច្រើនត្រូវគេមើលឃើញថានៅតែមានអំពើពុករលួយ និងក្រោមឥទ្ធិពលនយោបាយរបស់កម្ពុជា ។ លីកាដូ គាំទ្រការដោះស្រាយទំនាស់តាមរយៈប្រព័ន្ធច្បាប់ ប៉ុន្តែ ដោយសារភាពទន់ខ្សោយនៃតុលាការ អ្នកអង្កេតការណ៍ត្រូវពិនិត្យមើលអោយហួសពីការបង្ហាញតែសំបកក្រៅនៃភាពស្របច្បាប់ ដើម្បីសម្តែងអោយឃើញថាតើសិទ្ធិមនុស្ស កំពុងត្រូវបានរំលោភដោយវិធានការផ្លូវច្បាប់ដ៏មន្ទិល ឬយ៉ាងណា ។

ការចាប់ខ្លួនលោក ម៉ម សូណង់ដូ និងលោករ៉ុង ឈុន នៅខែតុលា (សូមមើលផ្នែកទី II ខាងលើ) មានកើតជាបន្តទៀត

---

[៣១] កាសែត Cambodge Soir ‘L’ONG Global Witness a fermé son bureau cambodgien’, ចេញផ្សាយថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ ។ ព្រឹត្តិបត្រ Cambodia Daily ចេញផ្សាយថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៥ ។

[៣២] ព័ត៌មានទទួលបានពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំនៅកម្ពុជា សម្ភាសន៍ជាមួយអ្នកការពារសិទ្ធិមនុស្សនៅ ADHOC ។

នៅខែធ្នូ ឆ្នាំ២០០៥ និងខែមករា ឆ្នាំ២០០៦ តាមរយៈការចាប់ខ្លួនសកម្មជនសិទ្ធិមនុស្សដ៏សំខាន់ ដែលត្រូវបានចោទប្រកាន់ពីការរិះគន់សន្ធិសញ្ញាព្រំដែនដ៏នេះ។ កង្វះការចូលរួម ដោយសកម្មណាមួយនៅក្នុងឧបទ្ទវហេតុ ដែលត្រូវបានចោទប្រកាន់អំពីបទបរិហារកេរ្តិ៍ និងលក្ខណៈនៃការចាប់ខ្លួនមន្ត្រីដឹកនាំថ្នាក់ខ្ពស់អ បង្ហាញពីការប៉ុនប៉ងរបស់រដ្ឋាភិបាល ដើម្បីរារាំងបុគ្គលសំខាន់ៗក្នុងសង្គមស៊ីវិល និងបំផ្លាញសិទ្ធិមនុស្សដែលពួកគេគាំទ្រ ។

លោក កឹម សុខា ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (Cambodian Center for Human Rights-CCHR) និងលោក យេង វីរៈ ប្រធានមជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ (Community Legal Education Center-CLEC) ត្រូវបានចាប់ខ្លួននៅក្រុងភ្នំពេញ នៅថ្ងៃទី៣១ ខែធ្នូ ហើយត្រូវចោទប្រកាន់ពីបទបរិហារកេរ្តិ៍[៣៣] ។ ការចាប់ខ្លួនអ្នកទាំងពីរនេះគឺពាក់ព័ន្ធនឹងបដាមួយដែលគេបានដាក់បង្ហាញនៅរោងពិធីរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា នៅទិវាសិទ្ធិមនុស្សអន្តរជាតិ ដែលបានរៀបចំឡើងនៅទីក្រុងភ្នំពេញកាលពីថ្ងៃទី១០ ខែធ្នូ ។ បដានោះ ដែលធ្លាប់បានចែកផ្សាយកន្លងមកតាមវេទិកាសាធារណៈរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅទូទាំងប្រទេស នៅអំឡុងពេលបោះឆ្នោតជាតិឆ្នាំ២០០៣ មានមតិរបស់អ្នកភូមិខ្មែរដែលសរសេរដោយដៃបង្ហាញពីមតិនយោបាយ ។ មានមតិមួយត្រូវបានចោទប្រកាន់ថា បានរិះគន់រដ្ឋាភិបាលស្តីពីបញ្ហាព្រំដែន។ លោក កឹម សុខា គឺជានាយកអង្គការ ដែលបានតាំងបង្ហាញបដានោះ ចំណែកឯលោក យេង វីរៈ ពុំមានការពាក់ព័ន្ធនឹងបដានោះ ក្រៅតែពីធ្វើជាប្រធានគណៈកម្មាធិការរៀបចំ ក្រុមសង្គមស៊ីវិលនានា ដែលបានរៀបចំពិធីប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិនោះទេ ។

នៅថ្ងៃទី ៤ ខែមករា ឆ្នាំ២០០៦ លោក ប៉ា ងួនទៀង នាយកផ្នែកកម្មវិធីវិទ្យុរបស់ CCHR (ដែលផ្សាយព័ត៌មានសិទ្ធិមនុស្ស) ត្រូវបានឃុំខ្លួនដោយគ្មានដីកានៅជិតព្រំដែនឡាវ ពាក់ព័ន្ធនឹងបដាដដែលនោះដែរ ។ បន្ទាប់មក លោកត្រូវចោទប្រកាន់ពីបទបរិហារកេរ្តិ៍ដែរ ។ ការចាប់ខ្លួនទាំងនេះបង្កើនអោយមានការព្រួយបារម្ភកាន់តែខ្លាំងឡើង អំពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលនៅក្នុងការត្រួតពិនិត្យសិទ្ធិមនុស្ស និងការមានឥទ្ធិពលទៅលើតុលាការកម្ពុជា ហើយជាការវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើអ្នកការពារសិទ្ធិមនុស្ស និងសេរីភាពបញ្ចេញមតិនៅកម្ពុជា ។

## ការវិវឌ្ឍនៅឆ្នាំ២០០៦

ប្រឈមមុខនឹងការធ្វើអន្តរាគមន៍ក្នុងស្រុក និងនៅលើឆាកអន្តរជាតិ[៣៤] លោកយេង វីរៈ ត្រូវបានដោះលែងអោយនៅក្រៅឃុំនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ ។ ៦ថ្ងៃក្រោយមកទៀត សម្តេចនាយករដ្ឋមន្ត្រី បានរៀបចំអោយមានការដោះលែងលោក កឹម សុខា លោក ប៉ា ងួនទៀង លោក ម៉ម សូណង់ដូ និងលោក រ៉ុង ឈុន អោយនៅក្រៅឃុំ ទុកដូចជា "កាដូ" ចំពោះឯកអគ្គ

[៣៣] សំអាងលើដីកាដែលគ្មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ ។ របាយការណ៍សង្ខេបរបស់លីកាដូ- កម្ពុជា : ការវាយប្រហារលើសេរីភាពបញ្ចេញមតិ និងសិទ្ធិនយោបាយ ថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ ទាក់ទងនឹងការចាប់ខ្លួនលោក ប៉ា ងួនទៀង នៅថ្ងៃទី០៤ ខែមករា ។

[៣៤] ព្រឹត្តិបត្រសារព័ត៌មាន Cambodia Daily ចេញផ្សាយថ្ងៃទី០៥, ១០, ១១, ១២ ខែមករា ។

រដ្ឋទូតសហរដ្ឋអាមេរិកនៅក្នុងឱកាសសម្ពោធស្ថានទូតថ្មី[៣៥] ។

ទោះបីមានលក្ខណៈត្រឹមត្រូវតាមបច្ចេកទេសក៏ដោយ តួនាទីរបស់សម្តេចនាយករដ្ឋមន្ត្រីជាអ្នកធានា ធ្វើអោយមានការច្របាច់បញ្ចូលគ្នានូវអំណាចនីតិប្រតិបត្តិ និងអំណាចតុលាការដោយសារមនុស្សដែលត្រូវបានចោទប្រកាន់ ត្រូវដោះលែងតែក្នុងករណីមានអន្តរាគមន៍ពីរូបលោក ហើយអ្នកដែលត្រូវដោះលែងនៅតែអាចត្រូវចាប់ខ្លួនវិញទៀត ប្រសិនបើ លោកដកការធានារបស់លោក ។ ជាការបង្ហាញពីចេតនាចង់បំបិទសម្លេងអ្នករិះគន់រថា រដ្ឋាភិបាលនឹងចាត់វិធានការនៅក្នុងករណីនេះ ប៉ុន្តែនឹងអនុញ្ញាតអោយមាន "អាជ្ញាយុកាល" រយៈពេល "បីឆ្នាំ"[៣៦] ដោយសង្កត់ធ្ងន់ថា តុលាការអាចបញ្ជាអោយចាប់ខ្លួនឡើងវិញនូវសកម្មជនណាមួយ ដែលប្រព្រឹត្តទង្វើ "ព្រហើន"[៣៧] ។ សម្តេចនាយករដ្ឋមន្ត្រីក៏មានប្រសាសន៍ដែរថា ការចោទប្រកាន់នោះទៀតក៏មិនអាចដកវិញបានដែរ[៣៨] ថ្វីបើធម្មតា ព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិ ថាត្រូវបន្ត ឬមិនបន្ត ប្រសិនបើបណ្តឹងត្រូវបានដករួចក៏ដោយ ។ ការផ្តល់សេរីភាពអោយនៅក្រៅឃុំនេះ ហាក់ដូចជាសេរីភាពចេញពីពន្ធនាគារ ជាថ្នូរនឹងការស្ងប់ស្ងាត់រយៈ ពេលបីឆ្នាំ ។

ការប៉ុនប៉ងយ៉ាងច្បាស់ក្រឡែតដើម្បីបំភិតបំភ័យ និងបំបិទសម្លេងសង្គមស៊ីវិលនៅកម្ពុជាបែបនេះ បាននាំអោយមានការថ្កោលទោសពីសំណាក់អង្គការសហប្រជាជាតិ រដ្ឋាភិបាលបរទេស ធនាគារពិភពលោក ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ។ ការចាប់ខ្លួន និងការឃុំខ្លួនទាំងនេះ បង្កើតអោយមានបរិយាកាសភ័យខ្លាចចំពោះសកម្មជនដែលនៅក្រៅឃុំដោយការធានា និងសមាជិកសង្គមស៊ីវិលដទៃទៀត ចំណែកឯសកម្មភាពរបស់រដ្ឋាភិបាលនៅទូទាំងឆ្នាំ២០០៥ បង្ហាញអោយឃើញនូវការមិនទទួលស្គាល់សិទ្ធិជាមូលដ្ឋានបំផុត ដែលចាំបាច់សំរាប់សង្គមសេរី និងប្រជាធិបតេយ្យ[៣៩] ។

---

[៣៥] ព្រឹត្តិបត្រសារព័ត៌មាន Cambodia Daily ចេញផ្សាយថ្ងៃទី១៨ ខែមករា ។

[៣៦] សន្ទរកថា នៅសាកលវិទ្យាល័យ Build Bright នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៦ ។ លោកនាយករដ្ឋមន្ត្រី ហាក់ដូចជាមានការយល់ច្រឡំអំពីអត្ថន័យនៃពាក្យ "អាជ្ញាយុកាល" ដែលចង់និយាយអំពីរយៈពេលអតិបរមាដែលនីតិវិធីព្រហ្មទណ្ឌអាចផ្តើមធ្វើឡើងក្រោយពីបានប្រព្រឹត្តិល្មើសដែលត្រូវបានចោទប្រកាន់ ។ នៅពេលដែល នីតិវិធីព្រហ្មទណ្ឌត្រូវបានចាប់ផ្តើមនៅក្នុងករណីទាំងនេះ ហើយការចាប់ខ្លួនត្រូវបានធ្វើឡើងតាមច្បាប់កម្ពុជា កាលកំណត់ដែលត្រូវកាត់ក្តីត្រូវធ្វើឡើង (ដោយ មិនគិត ថាជនជាប់ចោទត្រូវឃុំខ្លួន ឬយ៉ាងណា) គឺរយៈពេល៦ខែ ក្រោយពីថ្ងៃចាប់ខ្លួន (មាត្រា២១ នៃច្បាប់ UNTAC) ។

[៣៧] ព្រឹត្តិបត្រសារព័ត៌មាន Cambodia Daily ចេញផ្សាយថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ ។

[៣៨] ព្រឹត្តិបត្រសារព័ត៌មាន Cambodia Daily ចេញផ្សាយថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ២០០៦ ។

[៣៩] ធនាគារពិភពលោក របាយការណ៍ធនាគារពិភពលោកស្តីពីប្រទេសកម្ពុជា ចេញផ្សាយថ្ងៃទី ៩ ខែមករា ឆ្នាំ២០០៦ អង្គការលើកលែងទោសអន្តរជាតិ កម្ពុជា : ព័ត៌មានបន្ថែមស្តីពីអ្នកទោសមនសិការ/អ្នកការពារសិទ្ធិមនុស្ស ស្ថិតក្នុងហានិភ័យ ចេញផ្សាយថ្ងៃទី១៣ និង១៨ ខែមករា ឆ្នាំ២០០៦ លិខិតចំហនៅឱកាសទិវាសិទ្ធិមនុស្សអន្តរជាតិ ឆ្នាំ២០០៥ ដែលលើកពីការព្រួយបារម្ភ អំពីស្ថានភាពនៃសេរីភាពបញ្ចេញមតិនៅព្រះរាជាណាចក្រកម្ពុជា ចេញផ្សាយថ្ងៃទី១០ ខែមករា ឆ្នាំ២០០៦ អង្គការឃ្លាំមើលសិទ្ធិមនុស្ស "កម្ពុជា : សម្តេចនាយករដ្ឋមន្ត្រី-បំបិទសម្លេងរិះគន់មានលក្ខណៈជាប្រព័ន្ធចេញផ្សាយថ្ងៃទី ៤ ខែមករា ។ "កម្ពុជា : តុលាការត្រូវគេប្រើប្រាស់ដើម្បីបំបិទអ្នកប្រឆាំងនយោបាយ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៥ "កម្ពុជា : លោកនាយករដ្ឋមន្ត្រី ឈានទៅកំទេចអ្នកជំទាស់ចេញផ្សាយថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ ។

# IV. ផលប៉ះពាល់នៃការគំរាមកំហែងចំពោះការងារសិទ្ធិមនុស្ស

## ផលប៉ះពាល់ចំពោះសកម្មជនសិទ្ធិមនុស្ស

ការគំរាមកំហែងដែលមាននិយាយលំអិតនៅក្នុងផ្នែកទីIV ត្រូវបានរៀបចំឡើង ដើម្បីដាក់ទណ្ឌកម្ម បំភិតបំភ័យ និងបង្កឧបសគ្គដល់អ្នកបំរើការងារសិទ្ធិមនុស្ស ។ ជាលទ្ធផលចំពោះការគំរាមកំហែងទាំងនេះ អ្នកការពារសិទ្ធិមនុស្សអាចខ្លាចញញើតនឹងចូលក្នុងតំបន់ភូមិសាស្រ្តជាក់លាក់ណាមួយ ។ ពួកគេអាចនឹងស្ទាក់ស្ទើរក្នុងការដោះស្រាយករណីមួយចំនួន ឬមិនហ៊ានតាមដានការស៊ើបអង្កេតខ្លះ ។ ជួនកាលការគំរាមកំហែងទាំងនេះ ប្រព្រឹត្តិទៅដោយគ្មានការរាយការណ៍ទេ នាំអោយការការពារសិទ្ធិមនុស្សចុះខ្សោយដោយស្ងាត់ស្ងៀម ។ សមាជិកសង្គមស៊ីវិលខ្លះបានគេចខ្លួនទៅបរទេស ដើម្បីចៀសវាងការចាប់ខ្លួនដែលល្មើសនឹងកាតព្វកិច្ចការពារសិទ្ធិមនុស្សរបស់កម្ពុជារារាំងដល់ការពិភាក្សានយោបាយដោយសេរី និងដំណើរការសិទ្ធិមនុស្ស ដែលជាគ្រឿងទ្រទ្រង់ដល់លទ្ធិប្រជាធិបតេយ្យពិតប្រាកដ ។

និយាយអោយទូលំទូលាយជាងនេះទៅទៀត ការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្ស ប្រសិនបើអនុគ្រោះអត់អោន ឬប្រព្រឹត្តិដោយអាជ្ញាធររដ្ឋាភិបាល ជាពិសេសដោយមន្ត្រីអ្នកដឹកនាំថ្នាក់ខ្ពស់ខ្លះជាដើម បង្កើតអោយមានការមិនទុកចិត្តគ្នារវាងអ្នកតស៊ូមតិសិទ្ធិមនុស្ស និងមន្ត្រីរដ្ឋាភិបាល ។ ការណ៍នេះ កាត់បន្ថយសក្តានុពលសំរាប់អោយពួកគេធ្វើការរួមគ្នាដើម្បីសំរេចគោលដៅរួម ។ ទោះបីមានចំណុចដែលត្រូវកែលំអក៏ដោយ អង្គការមិនមែនរដ្ឋាធិបាលកម្ពុជា បានចរចាអោយមានទំនាក់ទំនងប្រកបដោយភាពសហការជាមួយអាជ្ញាធរមូលដ្ឋាននានា ដែលព្យាយាមពន្យល់អំពីជោគជ័យ ដែលអង្គការមិនមែនរដ្ឋាភិបាលសំរេចបានក្នុងវិស័យផ្សេងៗ ដូចជាការត្រួតពិនិត្យពន្ធនាគារ និងការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលសំរាប់នគរបាលបាលជាដើម ។ ប៉ុន្តែ ការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិ ធ្វើអោយខូចទំនាក់ទំនងប្រកបដោយផ្លែផ្កាទាំងនេះ ។

## ផលប៉ះពាល់ចំពោះសង្គម



សមាជិកសហគមន៍ក្បាល ស្ពានត្រូវបានឃុំខ្លួន

នៅពេលប្រជាពលរដ្ឋឃើញអ្នកការពារសិទ្ធិ ត្រូវគេចាប់ខ្លួន គំរាមកំហែង និងរំលោភបំពានដូច្នេះ ពួកគេមានការខ្លាចញញើតក្នុងការស្វែងរកសិទ្ធិមនុស្សរបស់ខ្លួនណាស់ ។ ជនរងគ្រោះបែរជាខ្លាចមិនហ៊ានស្វែងរកជំនួយពីក្រុមសិទ្ធិមនុស្ស ឬស្នើសុំអន្តរាគមន៍ពីនគរបាល និងដំណោះស្រាយតាមរយៈតុលាប្រឆាំងនឹងជនល្មើស ។ សមាជិកសហគមន៍ក៏អាចខ្លាចមិនហ៊ានចេញមុខអោយគេឃើញថា ធ្វើការជាមួយអង្គការសិទ្ធិមនុស្ស ឬរាយការណ៍ពីព័ត៌មានអំពីការរំលោភសិទ្ធិមនុស្សផងដែរ ។ អំពើពុករលួយដ៏ទុយិស និងកង្វះខាត ភាពមិនលំអៀង នៃប្រព័ន្ធតុលាការរឹតតែបង្កើនអោយមានការភ័យខ្លាចកាន់

តែច្រើនឡើង ។ បរិយាកាសបំភិតបំភ័យ និងនិទ្ទណ្ឌភាពធ្វើអោយជនរងគ្រោះ សាក្សី និងសមាជិកសហគមន៍ភិតភ័យមិនហ៊ានប្តឹងផ្តល់ចំពោះបុគ្គលមានអំណាច ឬធ្វើជាសាក្សីក្នុងករណីផ្សេងៗ ដោយសារភ័យខ្លាចពីការសងសឹក ជាលទ្ធផលប្រជាពលរដ្ឋគិតតែ "ប្រយ័ត្នប្រយែងចំពោះសិទ្ធិរស់នៅផ្ទាល់ ខ្លួន" តែប៉ុណ្ណោះ[៤០] ។

ការបំភិតបំភ័យក៏រួមចំណែកធ្វើអោយសាធារជននៅតែមានភាពស្ទាក់ស្ទើរក្នុងការសម្តែងមតិនយោបាយ ឬចូលរួមក្នុងការជំទាស់នយោបាយដោយសន្តិវិធីផងដែរ ។ ការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្ស ធ្វើអោយជំនឿរបស់ប្រជាពលរដ្ឋចំពោះសិទ្ធិមនុស្ស និងបំណងប្រាថ្នាទាមទារចង់បានសិទ្ធិទាំងនោះចុះថយជាខ្លាំង ។ ការណ៍នេះធ្វើអោយប្រជាពលរដ្ឋបាត់បង់សិទ្ធិក្នុងការចូលរួមដោយសេរី និងគ្មានការភ័យខ្លាចក្នុងដំណើរការប្រជាធិបតេយ្យ ។

ការវាយប្រហារមកលើអ្នកការពារសិទ្ធិមនុស្ស ច្រើនតែមានបំណងពីជនល្មើសដើម្បីបិទបាំងទង្វើរបស់គេ ឬដើម្បីរារាំងកុំអោយមានការស៊ើបអង្កេត ។ បើគ្មានអ្នកការពារសិទ្ធិមនុស្សទេ ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្សអាចនឹងត្រូវបង្ខំ ឬបំភិតបំភ័យអោយដកពាក្យបណ្តឹងរបស់ខ្លួនយ៉ាងងាយ ។ ដូច្នេះ ការការពារការងាររបស់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា គឺជាផ្នែកដ៏សំខាន់នៃកិច្ចប្រឹងប្រែង ដើម្បីដោះស្រាយបញ្ហានិទណ្ឌភាព និងកែលំអលទ្ធភាពទទួលបានយុត្តិធម៌ ។

---

[៤០] លោក នី ចរិយា នៃអង្គការសិទ្ធិមនុស្សកម្ពុជា ADHOC ដកស្រង់នៅក្នុងព្រឹត្តិបត្រសារព័ត៌មាន Cambodia Daily មានចំណងជើងថា "អង្គការមិនមែនរដ្ឋាភិបាលថ្លែងថាបណ្តឹងពីបទបរិហារកេរ្តិ៍ នាំអោយមានការភ័យខ្លាច" ចេញផ្សាយថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ២០០៥ ។

# V. អនុសាសន៍

លីកាដូ មានការព្រួយបារម្ភកាន់តែខ្លាំងឡើងអំពីការគំរាមកំហែង ការបំភិតបំភ័យ និងអំពើហិង្សាប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស ។ រដ្ឋាភិបាល គួរតែទទួលស្គាល់សារៈសំខាន់នៃអ្នកការពារសិទ្ធិមនុស្ស និងសង្គមស៊ីវិលក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ព្រមទាំងអនុញ្ញាតអោយសកម្មជនសិទ្ធិមនុស្សមានការរីកចំរើនឡើង ។ អំពើដាក់ទណ្ឌកម្មនិងជាឧបសគ្គបច្ចុប្បន្ននេះ ពិតជាមិនអាចទទួលយកបានទាំងស្រុង ។ ដោយឃើញមានលំនាំនៃការរំលោភបំពាន និងការគំរាមកំហែង ដែលបានប្រឈមមុខថ្មីៗនេះ លីកាដូ សូមជំរុញអោយមានវិធានការដូចតទៅនេះ :

### រាជរដ្ឋាភិបាលកម្ពុជា

- រដ្ឋាភិបាលគួរចាត់វិធានការជាបន្ទាន់ដើម្បីស៊ើបអង្កេត និងកាត់ទោសជនល្មើសដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តិអំពើហិង្សា និងការបំភិតបំភ័យ ចំពោះអ្នកការពារសិទ្ធិមនុស្ស ។
- រដ្ឋាភិបាលគួរអនុវត្តតាមការសន្យាគោរពច្បាប់ក្នុងស្រុក និងអន្តរជាតិទាំងឡាយរបស់ខ្លួន ជាពិសេសច្បាប់ទាំងឡាយដែលការពារសេរីភាពនៃការបញ្ចេញមតិ សេរីភាពក្នុងការប្រមូលផ្តុំដោយសន្តិវិធី សេរីភាពរួចផុតពីការឃុំខ្លួនដោយរំលោភបំពាន និងសិទ្ធិទទួលបាន និងផ្តល់ព័ត៌មាន ដែលមានសារៈសំខាន់បំផុតសំរាប់អ្នកការពារសិទ្ធិមនុស្ស ។
- រដ្ឋាភិបាលគួរគោរពលក្ខខណ្ឌនានានៃសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីអំពីអ្នកការពារសិទ្ធិមនុស្ស ឆ្នាំ១៩៩៨ ជាពិសេសមាត្រា៩ និង១២ ដែលចែងអំពីសិទ្ធិបុគ្គល និងអង្គភាពក្នុងការរិះគន់ និងប្រឆាំងតវ៉ានឹងសកម្មភាពរដ្ឋាភិបាល ព្រមទាំងតម្រូវអោយរដ្ឋផ្តល់កិច្ចការការដល់បុគ្គល និងអង្គភាពដែលស្ថិតក្រោមការគំរាមកំហែង ។
- សូមជំរុញអោយរដ្ឋាភិបាលដោះស្រាយទំនាស់នយោបាយជាមួយសង្គមស៊ីវិលតាមរយៈការចរចាដោយការទទួលខុសត្រូវ និងសូមជំរុញអោយគោរពកិច្ចព្រមព្រៀងក្រុងប៉ារីស រដ្ឋធម្មនុញ្ញកម្ពុជា និងកតិកាសញ្ញាអន្តរជាតិនានា ដែលកម្ពុជាជាភាគីមួយផងដែរ ។
- រដ្ឋាភិបាល គួរលុបចោលបញ្ញត្តិស្តីពីបទបរិហារកេរ្តិ៍ជាទោសព្រហ្មទណ្ឌ នៅក្នុងច្បាប់កម្ពុជា ។

### រដ្ឋាភិបាលបរទេស ស្ថានទូត និងម្ចាស់ជំនួយ

- រដ្ឋាភិបាលបរទេស ស្ថានទូត និងម្ចាស់ជំនួយ គួរទាមទារអោយរដ្ឋាភិបាលកម្ពុជា អនុវត្តទំនួលខុសត្រូវនានា ដែលមានចែងនៅក្នុងសេចក្តីប្រកាសរបស់អង្គការសហប្រជាតិស្តីអំពីអ្នកការពារសិទ្ធិមនុស្ស ។

- រដ្ឋាភិបាលបរទេស ស្ថានទូត និងម្ចាស់ជំនួយ គួរឆ្លើយតបចំពោះវិបត្តិសិទ្ធិមនុស្ស នៅពេលវិបត្តិទាំងនេះកើតមានឡើង និងធ្វើការជាមួយសង្គមស៊ីវិល ដើម្បីជំរុញអោយមានដំណោះស្រាយដែលនាំអោយប្រទេសកម្ពុជាអនុវត្តកាតព្វកិច្ចការពារសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន ។
- ក្នុងករណីមានការចាត់វិធានការផ្លូវច្បាប់ ដែលរៀបចំឡើងដើម្បីបំភិតបំភ័យអ្នកការពារសិទ្ធិមនុស្ស រដ្ឋាភិបាលបរទេស ស្ថានទូត និងម្ចាស់ជំនួយ គួរផ្តល់ព័ត៌មានដល់រដ្ឋាភិបាលកម្ពុជា ថាខ្លួនបានដឹងអំពីបណ្តឹង ដែលគ្មានមូលដ្ឋាន និងការចោទប្រកាន់ពីបទព្រហ្មទណ្ឌដោយការរំលោភបំពាន ដែលល្មើសនឹងកាតព្វកិច្ចផ្លូវច្បាប់ជាអន្តរជាតិ របស់កម្ពុជា ។ រដ្ឋាភិបាលបរទេស ស្ថានទូត និងម្ចាស់ជំនួយ គួរបញ្ជាក់អោយច្បាស់ចំពោះរដ្ឋាភិបាលកម្ពុជាថា ខ្លួនយល់ឃើញថាបណ្តឹងទាំងនោះត្រូវបានប្រើប្រាស់ ដើម្បីគំរាមកំហែងចំពោះបុគ្គលិកការងារសិទ្ធិមនុស្ស ។
- វិធានការគាំទ្រ អាចរួមមានការបញ្ចុះបញ្ចូលរដ្ឋាភិបាលកម្ពុជា ដោយទាមទារអោយលុបបំបាត់ឧបសគ្គផ្នែកច្បាប់ចំពោះការងារសិទ្ធិមនុស្ស និងការចូលរួមក្នុងដំណើរការកែសំរួលច្បាប់ព្រហ្មទណ្ឌកម្ពុជា ដើម្បីអោយស្របនឹងកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។

## អង្គការសិទ្ធិមនុស្សកម្ពុជា និងអន្តរជាតិ

- អង្គការសិទ្ធិមនុស្សកម្ពុជា និងអន្តរជាតិគួរបង្កើតអោយមានយន្តការការពាររយៈពេលខ្លី និងរយៈពេលវែងសំរាប់អ្នកការពារសិទ្ធិមនុស្ស ។ យន្តការទាំងនេះអាចរាប់បញ្ចូលការតស៊ូមតិ ការបង្កើតមូលនិធិក្នុងអាណត្តិភាពជួយសង្គ្រោះបន្ទាន់ ដើម្បីជួយឧបត្ថម្ភអ្នកដែលទទួលការគំរាមកំហែង ព្រមទាំងបង្កើតឡើងនូវ "បណ្តាញឆ្លើយតបជាបន្ទាន់" នៅថ្នាក់ជាតិ និងថ្នាក់តំបន់ ។
- ការបង្កើតបណ្តាញឆ្លើយតបជាបន្ទាន់នៅថ្នាក់តំបន់ គឺជាអាទិភាព ។ ប្រសិនបើសមស្រប បណ្តាញបែបនេះនឹងអាចចាត់វិធានការជាបន្ទាន់ ដើម្បីផ្សព្វផ្សាយពីការគំរាមកំហែង តស៊ូមតិប្រឆាំងនឹងអ្នកប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់ ព្រមទាំងផ្តល់នូវផែនការការពារអ្នកការពារសិទ្ធិមនុស្ស ប្រសិនបើចាំបាច់ ។
- យុទ្ធនាការតស៊ូមតិរួមគ្នា និងមានលក្ខណៈសំរបសំរួលគួរផ្តោតទៅលើការដាក់ស្ថានភាពកំពុងតែវិវឌ្ឍរបស់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា នៅក្នុងរបៀបវារៈអន្តរជាតិ ជាពិសេស របៀបវារៈរបស់អ្នកធ្វើការសំរេចចិត្តនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ អាស៊ាន និងស្ថាប័នប្រចាំតំបន់ និងរដ្ឋាភិបាលបរទេសនានាឯទៀត ។
- គួរលើកទឹកចិត្តអោយមានជាប្រព័ន្ធចងក្រងជាឯកសារនូវការគំរាមកំហែងទាំងឡាយចំពោះសន្តិសុខផ្ទាល់ខ្លួន និងសន្តិសុខវិជ្ជាជីវៈរបស់អ្នកការពារសិទ្ធិមនុស្ស ពិសេសអ្នកដែលធ្វើការតាមខេត្ត និងអង្គការតាមមូលដ្ឋាន ។ ការបង្កើនកិច្ចសហការរវាងអង្គការនានាមានសារៈសំខាន់ណាស់ ។ អង្គការតូចៗ និងអង្គការដែលមានធនធាននៅមានកំរិតគួរពិចារណារៀបចំយន្តការធ្វើរបាយការណ៍រួមគ្នា ។

# ឧបសម្ព័ន្ធទី ១ : តារាងឧប្បត្តិហេតុពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៥

## ឧបទ្ទវហេតុពាក់ព័ន្ធ នឹងការគំរាមកំហែងអ្នកការពារសិទ្ធិមនុស្ស

## នៅកម្ពុជា ឆ្នាំ២០០៥

| | |
|---|---|
| **ថ្ងៃទី ២០ ខែមករា ឆ្នាំ២០០៥** | **ការចាប់ខ្លួន និងការឃុំខ្លួនខុសច្បាប់សមាជិកសហជីពកម្មករ ពីរនាក់**[៤១]<br>▪ នៅថ្ងៃទី២០ ខែមករា លោកជា មន្នី ប្រធានសហជីពកម្មករសេរីនៃព្រះរាជាណាចក្រកម្ពុជា (Free Trade Union of Workers of the Kingdom of Cambodia-FTUWKC) និងលោកហេង សោភ័ណ តំណាង FTUWKC នៅរោងចក្រ Su Tong Fag ត្រូវបានចាប់ខ្លួនដោយនគរបាលនៅមុខការិយាល័យសហជីព ក្រោយមានបាតុកម្មមួយធ្វើឡើងដោយកម្មករកាត់ដេរដែលត្រូវបំបែកដោយនគរបាល ។ |
| **ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០០៥** | **អ្នកចូលរួមវេទិកាសិទ្ធិមនុស្ស ត្រូវឆែកឆេរដោយនគរបាល**[៤២]<br>▪ ក្រោយពីវេទិកាដោយសន្តិវិធីមួយរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា វាគ្មិននៅវេទិកានោះត្រូវគេបញ្ឈប់រថយន្ត និងឆែកឆេររកអាវុធនៅផ្លូវជាតិលេខ ៤ ។<br>▪ នគរបាលប្រាប់វាគ្មិនទាំងនោះថា ពួកគេទទួលបានព័ត៌មានថា ឯ.ឧ. សម សង្ស៊ី មេដឹកនាំគណបក្សជំទាស់បានលាក់អាវុធនៅក្នុងរថយន្តទាំងនោះ ។ នគរបាលពុំបានរកឃើញអាវុធនោះទេ ។ |
| **ថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ២០០៥** | **សកម្មជនព្រៃឈើនៅខេត្តក្រចេះត្រូវលោកអភិបាលស្រុកបញ្ជាអោយឈប់តវ៉ា**[៤៣]<br>▪ អភិបាលស្រុកអង្គស្នួលនៃខេត្តក្រចេះ បានបញ្ជាអោយអ្នកភូមិបញ្ឈប់ការបញ្ចុះបញ្ចូលជំទាស់ នឹងការទន្ទ្រានរំលោភដីដោយផ្តល់ជាឱវាទថា អ្នកភូមិទាំងនោះមិនមែនជាក្រុមសកម្មជនព្រៃឈើ ដែលបានចុះបញ្ជីផ្លូវការទេ ។<br>▪ កិច្ចប្រឹងប្រែងសុំចុះបញ្ជីផ្លូវការជាមួយអាជ្ញាធររបស់អ្នកភូមិ ត្រូវបដិសេធជាច្រើនលើកច្រើនសា ។ |
| **ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០៥** | **ការរឹបអូសរបាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល ជាការបដិសេធសេរីភាពនៃការបញ្ចេញមតិ**[៤៤] |

[៤១] របាយការណ៍ត្រួតពិនិត្យរបស់លីកាដូ ដែលមិនបានបោះពុម្ពផ្សាយ ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៥ "ការចាប់ខ្លួនលោកជា មន្នី និងលោក ហេង សោភ័ណ របាយការណ៍របស់ CCHR មិនបានបោះពុម្ពផ្សាយថ្ងៃទី ៧ ខែមករា ឆ្នាំ ២០០៥ " ការចងក្រងករណីស្តីពីសេរីភាពក្នុងការបង្កើតសមាគម ។"

[៤២] របាយការណ៍របស់ CCHR ដែលមិនបានបោះពុម្ពផ្សាយ "ការចងក្រងករណីស្តីពីសេរីភាពក្នុងការបង្កើតសមាគម" ថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៥ ។

[៤៣] ព្រឹត្តិបត្រសារព័ត៌មាន Cambodia Daily "ក្រុមសកម្មជនព្រៃឈើ ត្រូវបញ្ជាអោយបញ្ឈប់ការតវ៉ា" ចេញផ្សាយថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ២០០៥ ។

[៤៤] ព្រឹត្តិបត្រសារព័ត៌មាន Cambodia Daily "ការរារាំងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលបង្កអោយមានការខឹងសម្បាក្នុងចំណោមក្រុមអង្គការអន្តរជាតិ " ចេញផ្សាយ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៥ ។

| | |
|---|---|
| | ▪ របាយការណ៍របស់អង្គការ Global Witness ប្រមាណជា ២,១០០ច្បាប់អំពីអំពើពុករលួយជាស្ថាប័នមានលក្ខណៈជាប្រព័ន្ធទាក់ទងនឹងការរត់ពន្ធឈើខុសច្បាប់ត្រូវរឹបអូសដោយមន្ត្រីគយនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដោយគ្មានការពន្យល់អ្វីទាំងអស់ ។ របាយការណ៍នេះ មានបញ្ជីឈ្មោះមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល និងយោធាខ្លះដែលត្រូវចោទប្រកាន់ថាបានពាក់ព័ន្ធ នឹងការកាប់ឈើខុសច្បាប់ និងប្រព្រឹត្តអំពើពុករលួយ ។ |
| **ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០០៥** | **ការចាប់ខ្លួនខុសច្បាប់នៃសកម្មជនគណៈបក្សប្រឆាំងពីររូបនៅខេត្តកំពង់ឆ្នាំង** |
| | ▪ សកម្មជនគណបក្សសម រង្ស៊ីពីររូប ត្រូវចាប់ខ្លួនដោយគ្មានដីកានៅថ្ងៃទី២៨ ខែមិថុនា និងឃុំខ្លួនក្រោយពីបានជួយអ្នកភូមិតវ៉ាការដកហូតដីរបស់ពួកគេដោយក្រុមឯកជនមួយ ។ <br> ▪ ពួកគេត្រូវជាប់ទោសពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ប៉ុន្តែត្រូវបានដោះលែងនៅ ថ្ងៃទី ៥ ខែសីហា ។ |
| **ខែមិថុនា និង ខែកក្កដា ឆ្នាំ២០០៥** | **ការគំរាមកំហែងចំពោះបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងអ្នកដឹកនាំសហគមន៍នៅខេត្តមណ្ឌលគិរី**[៤៥] |
| | ▪ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងអ្នកដឹកនាំសហគមន៍ទទួលរងការគំរាមកំហែងក្រោយពីការតវ៉ានៅថ្ងៃទី ១៦ ខែមិថុនា និងថ្ងៃទី ៧ ខែកក្កដា ដោយជនជាតិដើមភាគតិចដែលរងគ្រោះ ដោយសម្បទានដីធ្លីទៅអោយក្រុមហ៊ុន Wuzhishan នៅខេត្តមណ្ឌលគិរី ។ <br> ▪ អាជ្ញាធរដែនដី ដាក់កំហិតទៅលើការងាររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិនៅខេត្តនេះ ។ គ្រប់អង្គការមិនមែនរដ្ឋាភិបាលទាំងអស់ត្រូវតម្រូវអោយប្រគល់អនុស្សារណៈ នៃការយោគយល់ដល់ក្រសួងដែលពាក់ព័ន្ធ ។ អភិបាលខេត្តតម្រូវអោយអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ជួបប្រជុំជាមួយលោករៀងរាល់ ៣ ខែម្តង ដើម្បីប្រគល់របាយការណ៍សកម្មភាពរបស់ខ្លួន ។ អ្នកដឹកនាំសហគមន៍ទាំងអស់ ត្រូវស្នើសុំការអនុញ្ញាតពីអភិបាលខេត្ត ដើម្បីចាកចេញពីខេត្ត និងដើម្បីចូលរួមការងារពាក់ព័ន្ធ នឹងអង្គការមិនមែនរដ្ឋាភិបាល[៤៦] ។ |
| **ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ២០០៥** | **ការគំរាមកំហែង និងការយាយីចំពោះសកម្មជនសិទ្ធិមនុស្សនៅខេត្តពោធិ៍សាត់**[៤៧] |
| | ▪ អ្នកស៊ើបអង្កេតចំនួន ៣ ពីសំណាក់អង្គការ LICADHO, CCHR, និង ADHOC ដែលសុទ្ធតែមានមូលដ្ឋាននៅខេត្តពោធិសាត់ត្រូវរារាំងមិនអោយថតរូប និងទទួលរងការ គំរាមកំហែងដោយការដកហូតម៉ាស៊ីនថត និងហ្វីលដោយអធិការរងនគរបាលស្រុកភ្នំក្រវាញ ។ |

[៤៥] Ibid

[៤៦] ព័ត៌មានទទួលបានពីការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំនៅកម្ពុជាកិច្ចសម្ភាសន៍ជាមួយអ្នកការពារសិទ្ធិមនុស្ស នៅអង្គការ ADHOC ។

[៤៧] ព្រឹត្តិបត្រសារព័ត៌មាន Cambodia Daily ថ្ងៃទី ៧ ខែកក្កដា របាយការណ៍ត្រួតពិនិត្យរបស់លីកាដូមិនទាន់បានបោះពុម្ពផ្សាយ ។

- អង្គការទាំងបីនេះ កំពុងត្រួតពិនិត្យការបំផ្លាញរបង និងដើមឈើជាកម្មសិទ្ធិរបស់គ្រួសារចំនួនពីរ ធ្វើឡើងដោយអាជ្ញាធរមូលដ្ឋាន ដែលមានគំរោងសាងសង់ផ្លូវមួយ ដោយគ្មានការយល់ព្រមពីគ្រួសារទាំងពីរ ។
- បុគ្គលិកអង្គការទាំងនោះ ត្រូវឃុំខ្លួនដោយអាជ្ញាធរចំនួនបីម៉ោង ។

**ថ្ងៃទី១០ ខែកក្កដា**

**ការប៉ុនប៉ងសម្លាប់សមាជិកសហគមន៍ព្រៃឈើ នៅខេត្តកំពង់ធំ**[៤៨]

- នៅឃុំទីរឹង ស្រុកសណ្តាន់ ខេត្តកំពង់ធំ សកម្មជនសហគមន៍ព្រៃឈើពីរនាក់ត្រូវគេបាញ់សម្លាប់ ។ អ្នកទាំងពីរពុំបានរងរបួសនៅក្នុងការបាញ់ប្រហារដាច់ដោយឡែកពីគ្នាទាំងពីរនេះ។ សមាជិកសហគមន៍ព្រៃឈើម្នាក់ដំបូងត្រូវគេបាញ់ ហើយបន្ទាប់មកទៀតត្រូវគេវាយដោយកាំភ្លើងនៅក្នុងការិយាល័យរដ្ឋបាលព្រៃឈើ ។
- សមាជិកសហគមន៍ព្រៃឈើម្នាក់ទៀត ត្រូវគេបាញ់ ពេលកំពុងនៅផ្ទះនៅល្ងាចថ្ងៃដដែលនោះ ។
- អំពើហិង្សានេះពាក់ព័ន្ធនឹងការព្យាយាមរបស់សមាជិកសហគមន៍ព្រៃឈើដើម្បីបញ្ឈប់អ្នកកាប់ឈើខុសច្បាប់ មិនអោយកាប់ដើមឈើដែលផ្តល់ជ័រនៅព្រឹកថ្ងៃដដែលនោះ ។ អ្នកកាប់ឈើខុសច្បាប់ នោះព្យាយាមសូកប៉ាន់សមាជិកសហគមន៍ព្រៃឈើ មុនការបាញ់ប្រហារលើកទីមួយ ។

**ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៥**

**ការគំរាមកំហែងដល់អាយុជីវិតរបស់ប្រធានសមាគមសហគមន៍**[៤៩]

- លោកស្រី ដំ ចន្នី ប្រធានសមាគមជនជាតិភ្នំ ដែលធ្វើការដើម្បីអប់រំជនជាតិភាគតិចអំពីសិទ្ធិដីធ្លី គឺជាជនរងគ្រោះនៃការគំរាមកំហែងជាញឹកញាប់ទាក់ទងនឹងការងាររបស់លោក ស្រី[៥០] ។
- នគរបាលម្នាក់ត្រូវគេបាញ់ស្លាប់ នៅខេត្តរតនគិរីនៅពេលព្យាយាមតាមចាប់បុគ្គលម្នាក់ ដែលគេសង្ស័យថាព្យាយាមសម្លាប់អ្នកស្រី ដំ ចន្នី ។
- ជនសង្ស័យនោះ ត្រូវសម្លាប់ដោយនគរបាលនៅក្នុងការប្រយុទ្ធដោយអាវុធ នៅមុនពេលគេអាចអះអាងថាគាត់ធ្វើការអោយនរណា[៥១] ។

**ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៥**

**ការបដិសេធមិនអោយបុគ្គលិកអង្គការ Global Witness ចូលប្រទេស និងការដកហូតទិដ្ឋាការ**[៥២]

- ថ្ងៃទី១៨ ខែកក្កដា បុគ្គលិកបរទេសរបស់អង្គការ **Global Witness** ត្រូវបានបដិសេធមិន

---

[៤៨] ព័ត៌មានទទួលបានពីការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំនៅកម្ពុជា ។

[៤៩] ព្រឹត្តិបត្រសារព័ត៌មាន ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៥ ។

[៥០] ព្រឹត្តិបត្រសារព័ត៌មាន ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៥ ទំព័រ ១៩ ។

[៥១] ព្រឹត្តិបត្រសារព័ត៌មាន ថ្ងៃទី៦-៧ ខែសីហា ឆ្នាំ២០០៥ ។

[៥២] ព្រឹត្តិបត្រសារព័ត៌មាន ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៥ ។

| | |
|---|---|
| | អោយចូលប្រទេសកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅពេលត្រឡប់មកពីក្រុងបាងកក ហើយទិដ្ឋាការរបស់គាត់ត្រូវបានលុបចោលដោយគ្មានការពន្យល់ហេតុផល ។<br>▪ នៅដំណាច់ខែកក្កដា ក្រសួងការបរទេសបានប្រកាសថា អង្គការ Global Witness លែងទទួលបានការស្វាគមន៍នៅក្នុងប្រទេសកម្ពុជាទៀត ហើយនិយោជិតទាំង ៥នាក់ត្រូវចុះនៅក្នុង "បញ្ជីខ្មៅ" ។<br>▪ ដោយសារមានការគំរាមកំហែង និងការបង្កជាឧបសគ្គជាច្រើនលើក អង្គការមិនមែនរដ្ឋាភិបាលនេះក៏បិទការិយាល័យនៅកម្ពុជារបស់ខ្លួននៅខែតុលា[៥៣] ។ |
| **ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៥** | **វេទិកា CCHR ត្រូវបិទដោយនគរបាលនៅកំពង់សោម**[៥៤] |
| | ▪ វេទិកាសាធារណៈរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (Cambodian Center for Human Rights - CCHR) មួយ ដែលប្រជាពលរដ្ឋប្រមាណជា ១, ០០០ នាក់ ចូលរួមត្រូវបិទក្រោយពីមានក្រុមមនុស្សប្រមាណជា ៤០នាក់ស្រែកពាក្យស្លោកគាំទ្ររដ្ឋាភិបាល និងបង្ហាញកាយវិការក្រេវក្រោធដាក់គណៈវាគ្មិន ។<br>▪ នគរបាលបិទវេទិកាដោយសារមាន "ភាពចលាចល" ។ |
| **ថ្ងៃទី ២៦ និង ២៩ ខែសីហា ឆ្នាំ២០០៥** | **ការរំខានកិច្ចប្រជុំស្តីពីសិទ្ធិមនុស្សនៅក្រុងកំពង់សោម**[៥៥] |
| | ▪ នគរបាលប៉ុនប៉ងបិទកិច្ចប្រជុំមួយ រៀបចំដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា នៅថ្ងៃទី២៦ ខែសីហា ។<br>▪ នៅថ្ងៃទី២៩ ខែសីហា អាជ្ញាធរដែនដីមានការពាក់ព័ន្ធក្នុងការរំខានកិច្ចប្រជុំឯកជនមួយ ដែលរៀបចំដោយ **CCHR** ដោយបើកសម្លេងភ្លេងខ្លាំងៗ ។ |
| **ថ្ងៃទី ២៦ ខែកញ្ញា កាលបរិច្ឆេទឆ្នាំ២០០៥** | **បណ្តឹងពីបទផ្សាយព័ត៌មានមិនពិតប្រឆាំងនឹងអ្នកសំរបសំរួលអង្គការ ADHOC នៅខេត្តរតនគិរី**[៥៦] |
| | ▪ នៅខេត្តរតនគិរី អ្នកសំរបសំរួលនៅអង្គការ **ADHOC** ប្រឈមមុខនឹងបណ្តឹងពីបទផ្សាយព័ត៌មានមិនពិត ក្រោយពីផ្តល់កិច្ចសម្ភាសន៍ដល់វិទ្យុអាស៊ីសេរី អំពីអន្តរាគមន៍របស់លោកក្នុងទំនាស់ដីធ្លីរវាងជនជាតិដើមចំនួន ១១០គ្រួសារ និងមន្ត្រីយោធាមួយរូបនៅឃុំឯកភាព ស្រុកអូរជុំ ។<br>▪ ក្រុមគ្រួសារទាំងនោះ ត្រូវបានគេបង្ខំអោយលក់ដីរបស់ខ្លួនក្នុងតម្លៃទាបទៅអោយមន្ត្រីយោធា |

[៥៣] កាសែត Cambodge Soir ចេញផ្សាយអត្ថបទមានចំណងជើងថា, 'L'ONG Global Witness a fermé son bureau cambodgien' នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ ។

[៥៤] របាយការណ៍សង្ខេបរបស់លីកាដូ មានចំណងជើងថា "ការរឹតត្បិតសេរីភាពក្នុងការប្រមូលផ្តុំនៅកម្ពុជា" ចេញផ្សាយខែធ្នូ ឆ្នាំ ២០០៥ ។

[៥៥] របាយការណ៍សង្ខេបរបស់លីកាដូ មានចំណងជើងថា "ការរឹតត្បិតសេរីភាពក្នុងការប្រមូលផ្តុំនៅកម្ពុជា" ចេញផ្សាយខែធ្នូ ឆ្នាំ ២០០៥ ។

[៥៦] Ibid

នោះ ហើយអ្នកសំរបសំរួលអង្គការ ADHOC បានធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរ ដើម្បីបញ្ឈប់សកម្មភាពឈូសឆាយដីដែលមានជម្លោះនោះ ។ នៅពេលបោះពុម្ពផ្សាយរបាយការណ៍នេះ ករណីនេះរង់ចាំការដោះស្រាយនៅតុលាការនៅឡើយ ។

**ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០០៥**

**ទាហានបាញ់អ្នកភូមិដែលតវ៉ារឿងទំនាស់ដីធ្លីនៅខេត្តបាត់ដំបង**[៥៧]

- ទាហាន ៨ នាក់ នៅកងពលតូចលេខ ៥៣ នៃកងយុទ្ធពលខេមរភូមិន្ទ បានបាញ់អ្នកតវ៉ានៅអំឡុងទំនាស់ដីធ្លីមួយ ។ មានអ្នកតវ៉ាមួយចំនួនរងរបួសម្នាក់ត្រូវអោយកាត់ម្រាមដៃចេញ ។
- កងយុទ្ធពលខេមរភូមិន្ទ បានដាក់របាំងបិទផ្លូវទៅកាន់ដីនោះ ដែលមានទំហំរាប់ម៉ឺនហិកតា ដែលមានទំនាស់ជាមួយប្រជាពលរដ្ឋ ១,៦៥៦ គ្រួសារ ។
- ទាហានរារាំងអ្នកភូមិដែលប៉ុនប៉ងទៅសួរសុខទុក្ខតំណាងរបស់ខ្លួនដែលត្រូវចាប់ខ្លួនដោយខុសច្បាប់កាលពីមួយសប្តាហ៍មុន ។ អំពើហិង្សា ចាប់ផ្តើមឡើងនៅពេលទាហានព្យាយាមចាប់ខ្លួនតំណាងម្នាក់ទៀតដោយខុសច្បាប់ ប៉ុន្តែ ពួកគេត្រូវរាំងផ្លូវដោយអ្នកភូមិដែលកំពុងតវ៉ា ។

**ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៥**

**ការចាប់ខ្លួន និងការឃុំខ្លួន លោក កឹម សុខា និងលោក យេង វីរៈ**[៥៨]

- លោក កឹម សុខា ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្ស កម្ពុជា (Cambodian Center for Human Rights-CCHR) និងលោក យេង វីរៈ ប្រធានមជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ (Community Legal Education Center-CLEC) ត្រូវចាប់ខ្លួននៅ ថ្ងៃទី៣១ ខែធ្នូ ។ ការចាប់ខ្លួនអ្នកទាំងពីរពាក់ព័ន្ធនឹងបដាមួយ ដែលតាំងបង្ហាញនៅរោងពិធីរបស់ CCHR នៅអំឡុងទិវាសិទ្ធិមនុស្សអន្តរជាតិ ដែលរៀបចំធ្វើនៅក្រុងភ្នំពេញ នៅថ្ងៃទី១០ ខែធ្នូ ។ លោក យេង វីរៈ ប្រធានគណៈកម្មាធិការបង្កើតក្រុមសង្គមស៊ីវិលផ្សេងៗ ដែលរៀបចំពិធីប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ ។
- បដានេះ ធ្លាប់បានផ្សព្វផ្សាយកន្លងមកដោយ CCHR នៅទូទាំងប្រទេស ហើយនៅតាមវេទិកាសាធារណៈ នានានៅអំឡុងពេលបោះឆ្នោតជាតិឆ្នាំ២០០៣ ។ បដានេះសរសេរដោយដៃអ្នកភូមិដែលសម្តែងមតិនយោបាយ ។ នៅក្នុងមតិមួយនោះមានរិះគន់រដ្ឋាភិបាល និងនិយាយពីបញ្ហាព្រំដែន ។
- អ្នកទាំងពីរត្រូវចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ផ្អែកតាមបណ្តឹងរបស់រដ្ឋាភិបាល ។ អ្នកទាំងពីរត្រូវចាប់ខ្លួនដោយខុសច្បាប់ ដោយសំអាងលើដីកាចាប់ខ្លួនដែលមិនមានលក្ខណៈសមស្របតាម

[៥៧] របាយការណ៍សង្ខេបរបស់លីកាដូ មានចំណងជើងថា "ការរឹតត្បិតសេរីភាពក្នុងការប្រមូលផ្តុំនៅកម្ពុជា" ចេញផ្សាយខែធ្នូ ឆ្នាំ ២០០៥ ។

[៥៨] របាយការណ៍សង្ខេបរបស់លីកាដូ ក្រោមចំណងជើងថា "កម្ពុជា : ការវាយប្រហារទៅលើសេរីភាពបញ្ចេញមតិ និងសិទ្ធិនយោបាយ" ចេញផ្សាយនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ ។

[៥៩] របាយការណ៍សង្ខេបរបស់លីកាដូ ក្រោមចំណងជើងថា "កម្ពុជា : ការវាយប្រហារទៅលើសេរីភាពបញ្ចេញមតិ និងសិទ្ធិនយោបាយ" ចេញផ្សាយនៅថ្ងៃ ១១ ខែមករា ឆ្នាំ២០០៦ ។

ផ្លូវច្បាប់[៥៩] ។

**ថ្ងៃទី ៤ ខែមករា ឆ្នាំ២០០៦**

**ការចាប់ខ្លួន និងការឃុំខ្លួនលោក ប៉ា ងួនទៀង នាយកផ្នែកកម្មវិធីវិទ្យុនៃ CCHR**[60]

- លោក ប៉ា ងួនទៀង ត្រូវចាប់ខ្លួននៅខេត្តស្ទឹងត្រែង ក្បែរព្រំប្រទល់ប្រទេសឡាវ ជាប់ពាក់ព័ន្ធ នឹងបដាដែលលើកបង្ហាញនៅទិវាសិទ្ធិមនុស្សអន្តរជាតិ ។
- ភាពស្របច្បាប់នៃការចាប់ខ្លួន និងការឃុំខ្លួននេះបាននាំអោយមានការងឿងឆ្ងល់ដោយសារការចាប់ខ្លួននោះគ្មានដីកា ហើយតាមរបាយការណ៍ លោកត្រូវចាប់ខ្លួនតាមបញ្ជារបស់ក្រសួងមហាផ្ទៃ ។ លោកត្រូវចោទប្រកាន់នៅក្នុងតុលាការពីបទបរិហារកេរ្តិ៍នៅថ្ងៃទី ៥ ខែមករា ។

**ថ្ងៃទី១៧-៣១ ខែមករា ឆ្នាំ២០០៦**

**ការបំភិតបំភ័យសកម្មជនដែលត្រូវធានាអោយនៅក្រៅឃុំ**[៦១]

- សម្តេចនាយករដ្ឋមន្ត្រីហាក់ដូចប៉ុនប៉ងបំបិទសម្លេងសកម្មជន ដោយប្រើប្រាស់ឥទ្ធិពលរបស់លោកតាមមធ្យោបាយមួយចំនួន ដែលធ្វើអោយខូចតម្លៃការបែងចែករវាងអំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។
- សម្តេចនាយករដ្ឋមន្ត្រីបានធានាសកម្មជន មានលោកកឹម សុខា និងលោកប៉ា ងួនទៀង លោក ម៉ម សូណង់ដូ និងលោករ៉ុង ឈុន អោយនៅក្រៅឃុំ ។ ទោះបីផ្តល់លទ្ធភាពអោយមានការដោះលែងអ្នកទាំងនេះក៏ដោយ ហេតុការណ៍នេះក៏បញ្ជាក់ថាសម្តេចនាយករដ្ឋមន្ត្រីអាចដកការធានានៅពេលណាមួយក៏បាន ដើម្បីអោយគេចាប់ខ្លួនអ្នកទាំងនេះសារជាថ្មី ។
- សម្តេចនាយករដ្ឋមន្ត្រីបានស្នើអោយតុលាការ គួរបង្អង់ដំណើរការនៃករណីនេះសិន ហើយលោកថ្លែងថារដ្ឋាភិបាលអាចរក្សាទុកករណីនេះអោយនៅ "ស្ងៀមស្ងាត់"។ ប៉ុន្តែ លោកបន្ថែមផងដែរថា សកម្មជនណាដែលប្រព្រឹត្ត "ព្រហើន" នឹងត្រូវចាប់ខ្លួន ។

---

[៦០] របាយការណ៍សង្ខេបរបស់លីកាដូ ក្រោមចំណងជើងថា "កម្ពុជា : ការវាយប្រហារទៅលើសេរីភាពបញ្ចេញមតិ និងសិទ្ធិនយោបាយ" ចេញផ្សាយនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ ។

[៦១] ព្រឹត្តិបត្រសារព័ត៌មាន Cambodia Daily មានចំណងជើងថា "លោកនាយករដ្ឋមន្ត្រីទៅកាន់សកម្មជន : បើមិនស្ងៀមទេ កុំសង្ឃឹមថាទទួលការលើកលែងទោស" ចេញផ្សាយថ្ងៃទី១៨ ៣១ ខែមករា ឆ្នាំ២០០៦ និងថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ២០០៦ ។